ធនាគារជាតិ នៃ កម្ពុជា
ប្រាក់រៀល ស្ថិរភាព អភិវឌ្ឍន៍

# របាយការណ៍ត្រួតពិនិត្យ
# ប្រចាំឆ្នាំ ២០១៧

អគ្គនាយកដ្ឋានត្រួតពិនិត្យ



# អារម្ភកថា

ស្របគ្នានឹងការងើបឡើងនៃសេដ្ឋកិច្ចប្រទេសអភិវឌ្ឍន៍និងកំណើនខ្ពស់នៃសេដ្ឋកិច្ចប្រទេសកំពុងលូតលាស់ សេដ្ឋកិច្ចកម្ពុជានៅតែរក្សាបានកំណើនប្រមាណ ៦,៩% នៅក្នុងឆ្នាំ២០១៧ ហើយកំណើននេះត្រូវបានព្យាករណ៍ថា ស្ថិតក្នុងរង្វង់ដដែលសម្រាប់រយៈពេលមធ្យមខាងមុខ។ វិស័យសំខាន់ៗមួយចំនួនបានដើរតួនាទីយ៉ាងសំខាន់ក្នុងការទ្រទ្រង់ដល់សេដ្ឋកិច្ចជាតិ ដូចជា វិស័យទេសចរណ៍ កាត់ដេរសម្លៀកបំពាក់ សំណង់ និងកសិកម្ម ដែលមានការកើនឡើងជាងឆ្នាំមុនៗបន្តិច ហើយការនាំចេញផលិតផលឧស្សាហកម្មផ្សេងទៀត ក៏បានរួមចំណែកដល់ការរីកចម្រើននេះផងដែរ។ សមិទ្ធផលដែលបន្តសម្រេចបានខាងលើ គឺអាស្រ័យលើកត្តាចម្បង ៣ រួមមាន សន្តិភាពនិងស្ថិរភាពនយោបាយ គោលនយោបាយទាក់ទាញការវិនិយោគនិងទេសចរណ៍ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ តាមរយៈការរីកចម្រើននៃសេដ្ឋកិច្ចនិងស្ថិរភាពហិរញ្ញវត្ថុ វិនិយោគិនទាំងក្នុងស្រុកនិងក្រៅប្រទេសបានពង្រីកការវិនិយោគរបស់ខ្លួនមកលើវិស័យធនាគារ ដែលមានភាពរឹងមាំនិងបរិយាប័ន្ន និងជំរុញឱ្យវិស័យធនាគារកាន់តែដើរតួនាទីសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ដោយផ្តល់សេវាហិរញ្ញវត្ថុដែលមានប្រសិទ្ធភាពនិងទូលំទូលាយជាងមុន។

ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យ ធនាគារជាតិនៃកម្ពុជាបានបន្តយកចិត្តទុកដាក់ក្នុងការពង្រឹងប្រសិទ្ធភាពនៃការត្រួតពិនិត្យ និងភាពរឹងមាំនៃប្រព័ន្ធធនាគារ ស្របតាមការអភិវឌ្ឍនៃស្ថានភាពអាជីវកម្មរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនាពេលបច្ចុប្បន្ន និងការវិវឌ្ឍន៍នៃកំណែទម្រង់អន្តរជាតិទាក់ទងនឹងការត្រួតពិនិត្យ។ បន្ថែមលើការត្រួតពិនិត្យផ្អែកលើបទប្បញ្ញត្តិ និងការត្រួតពិនិត្យផ្អែកលើហានិភ័យ និងទស្សនៈអនាគត ធនាគារជាតិនៃកម្ពុជាក៏យកចិត្តទុកដាក់លើការពង្រឹងបទប្បញ្ញត្តិផងដែរ ដូចជា ការដាក់ចេញនូវប្រកាសស្តីពី ក្របខ័ណ្ឌគ្រប់គ្រងហានិភ័យសន្ទនីយភាពរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងប្រកាសមួយចំនួនស្របតាមគោលការណ៍គ្រឹះបាសែល។ ធនាគារជាតិនៃកម្ពុជាក៏បានដាក់ឱ្យអនុវត្តពិដានអត្រាការប្រាក់ចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនិងឥណទានជនបទ ក្នុងអត្រា ១៨% ដែលបង្កលក្ខណៈអំណោយផលដល់ប្រជាកសិករ និងសហគ្រាសធុនតូចនិងមធ្យម ឱ្យទទួលបានហិរញ្ញប្បទានក្នុងតម្លៃទាបជាងមុន និងបានសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីដាក់បញ្ចូលចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាចំណេះដឹងទូទៅ។ ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជាបានបន្តអភិវឌ្ឍប្រព័ន្ធទូទាត់ដោយផ្អែកលើបច្ចេកវិទ្យាទំនើប ដូចជា ការពង្រឹងសេវាទូទាត់រហ័ស (Fast Payment System) ដែលប្រព័ន្ធនេះអាចឱ្យអតិថិជនទទួលបានមូលនិធិភ្លាមៗ ឆ្លើយតបទៅនឹងតម្រូវការសាច់ប្រាក់បានទាន់ពេលវេលា ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ Cambodian Shared

Switch (CSS) ដែលជាប្រព័ន្ធរួមមួយសម្រាប់សម្រួលដល់ប្រតិបត្តិការទូទាត់អន្តរធនាគារ តាមរយៈការប្រើប្រាស់បណ្តាញទូទាត់ជាមួយម៉ាស៊ីន ATM និងម៉ាស៊ីន POS ដើម្បីបង្កើនប្រសិទ្ធភាពសេវាទូទាត់ លើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ និងកាត់បន្ថយចរាចរសាច់ប្រាក់នៅលើទីផ្សារ ព្រមទាំងកំពុងសិក្សាបង្កើតប្រព័ន្ធទូទាត់ដុលភ្លាមៗ (Real Time Gross Settlement-RTGS)។ បន្ថែមលើនេះ ដើម្បីដាក់ចេញនូវវិធានការសមស្របនិងទាន់ពេលវេលាក្នុងការកែតម្រូវនិងទប់ស្កាត់ហានិភ័យរបស់គ្រឹះស្ថាននីមួយៗនិងប្រព័ន្ធធនាគារទាំងមូល ធនាគារជាតិនៃកម្ពុជាបានបន្តយកចិត្តទុកដាក់ក្នុងការពង្រឹងសមត្ថភាពរបស់មន្ត្រីត្រួតពិនិត្យ ទាំងចំណេះដឹងផ្នែកជំនាញនិងផ្នែកទ្រឹស្តី។

ក្នុងគោលដៅឈានទៅអនុវត្តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិកម្ពុជា ធនាគារជាតិនៃកម្ពុជាបានកែសម្រួលបទប្បញ្ញត្តិទាក់ទងនឹងការធ្វើចំណាត់ថ្នាក់ឥណទាន និងការធ្វើសំវិធានធនលើអ៊ីមភែរមិន។ ជាមួយគ្នានេះ ក្នុងការគាំទ្រការអភិវឌ្ឍប្រព័ន្ធចែករំលែកឥណទានរបស់ក្រុមហ៊ុនក្រេឌីតប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី ធនាគារជាតិនៃកម្ពុជាបានចេញសេចក្តីជូនដំណឹងដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ស្តីពីការផ្តល់ព័ត៌មានឥណទានក្រុមហ៊ុន សម្រាប់សាកល្បងឱ្យសមាជិកអាចបញ្ចូលនិងទាញយកព័ត៌មានឥណទានក្រុមហ៊ុនបន្ថែមលើព័ត៌មានបុគ្គល។ ក្នុងការពង្រឹងចំណេះដឹងផ្នែកហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបានយកចិត្តទុកដាក់ចំពោះការបញ្ជ្រាបចំណេះដឹងទាំងនេះទៅក្នុងកម្មវិធីសិក្សាទូទៅ ស្របតាមផែនការកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា ហើយកិច្ចការពារអតិថិជនត្រូវបានយកចិត្តទុកដាក់បន្ថែម តាមរយៈការបង្កើតក្រុមការងារគាំពារអតិថិជន និងប្រព័ន្ធ Hotline។ ក្នុងការលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីវិស័យមីក្រូហិរញ្ញវត្ថុ នៅខេត្តកំពង់ចាមនិងខេត្តកណ្តាល ព្រមទាំងសហការជាមួយការិយាល័យមូលនិធិរូបិយវត្ថុអន្តរជាតិប្រចាំតំបន់អាស៊ី-ប៉ាស៊ីហ្វិក (OAP) រៀបចំសិក្ខាសាលាថ្នាក់តំបន់ស្តីពីបរិយាប័ន្នហិរញ្ញវត្ថុ ដោយបង្ហាញអំពីទំនាក់ទំនងរវាងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងបរិយាប័ន្នហិរញ្ញវត្ថុ។ ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥ ធនាគារជាតិនៃកម្ពុជាកំពុងសិក្សាលើក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិដែលពាក់ព័ន្ធនឹងការបង្កើតប្រព័ន្ធការពារប្រាក់បញ្ញើផ្អែកលើគំរូ Pay Box Plus។ ខ្ញុំសង្ឃឹមថារបាយការណ៍នេះ នឹងអាចប្រើប្រាស់ជាឯកសារសម្រាប់បង្កើនការយល់ដឹងដល់អ្នកសិក្សាស្រាវជ្រាវ ក៏ដូចជាផ្តល់ព័ត៌មានដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីស្វែងយល់ពីលទ្ធផលនិងប្រសិទ្ធភាពនៃការអនុវត្តការងាររបស់ខ្លួន។

ថ្ងៃសុក្រ ៦កើត ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៨

**ជា ចាន់តូ**

**ទេសាភិបាល**

**ធនាគារជាតិនៃកម្ពុជា**

# មាតិកា

**អារម្ភកថា** ........ i
**បញ្ជីរូបភាពនិងតារាង** ........ v
**១. ការអភិវឌ្ឍសំខាន់ៗនៃវិស័យធនាគារ** ........ ១
១.១. ទិដ្ឋភាពទូទៅនៃគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ........ ១
១.២. ស្ថានភាព និងប្រតិបត្តិការហិរញ្ញវត្ថុ ........ ៤
១.២.១. ប្រតិបត្តិការនៃវិស័យធនាគារ ........ ៤
១.២.២. ប្រតិបត្តិការនៃវិស័យមីក្រូហិរញ្ញវត្ថុ ........ ៦
១.២.៣. ប្រតិបត្តិការនៃវិស័យភតិសន្យាហិរញ្ញវត្ថុ ........ ៨
១.២.៤. ប្រតិបត្តិការនៃអាជីវកម្មប្តូរប្រាក់ ........ ៩
១.២.៥. វឌ្ឍនភាពនៃការងារចុះបញ្ជីគ្រឹះស្ថានឥណទានជនបទ ........ ១០
**២. ការវិវឌ្ឍន៍ក្របខ័ណ្ឌនៃការត្រួតពិនិត្យនិងបទប្បញ្ញត្តិ** ........ ១០
២.១. ការពិនិត្យឡើងវិញ និងការដាក់ចេញនូវបទប្បញ្ញត្តិ ........ ១០
២.១.១. ការដាក់ស្លាកសញ្ញា "គ្រឹះស្ថានឯកជន" បង្ហាញសាធារណជន ........ ១១
២.១.២. ការស្នើសុំប្តូរនិមិត្តសញ្ញារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានឥណទានជនបទ ........ ១១
២.១.៣. ការកំណត់ពិដានអត្រាការប្រាក់ឥណទាន ........ ១២
២.១.៤. ការដោះស្រាយបណ្តឹងអតិថិជនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ........ ១២
២.១.៥. លក្ខខណ្ឌសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដាក់ពាក្យសុំចុះបញ្ជីលក់មូលបត្រក្នុងផ្សារមូលបត្រកម្ពុជា ........ ១២
២.១.៦. ក្របខ័ណ្ឌគ្រប់គ្រងសន្ទនីយភាពរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ........ ១៣
២.១.៧. ការផ្តល់វិញ្ញាបនបត្រចំពោះគ្រឹះស្ថានឥណទានជនបទ ........ ១៣
២.១.៨. សវនកម្មចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ. ........ ១៤
២.១.៩. ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមភែរមិន ........ ១៤
២.២. សកម្មភាពនៃការត្រួតពិនិត្យ ........ ១៥
**៣. ការជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងសមាហរណកម្មក្នុងតំបន់** ........ ១៦
៣.១. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ ........ ១៦
៣.១.១. ស្តង់ដារគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ ........ ១៦
៣.១.២. ការិយាល័យព័ត៌មានឥណទានកម្ពុជា ........ ១៦

៣.១.៣. ប្រតិបត្តិការប្រព័ន្ធទូទាត់ ........................................................................ ១៧
៣.២. ការងារបរិយាប័ន្នហិរញ្ញវត្ថុ ........................................................................ ១៨
៣.៣. ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងកិច្ចការពារអតិថិជន ........................................................ ១៩
៣.៤. ការអភិវឌ្ឍទីផ្សារអន្តរធនាគារ ........................................................................ ២១
៣.៥. ការផ្តល់ហិរញ្ញប្បទានដល់វិស័យអចលនទ្រព្យ ........................................................ ២២
៣.៦. យន្តការការពារអ្នកដាក់ប្រាក់បញ្ញើ ........................................................................ ២៤
**៤. ការកសាងសមត្ថភាពត្រួតពិនិត្យ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ** ........................................ ២៥
៤.១. ការកសាងសមត្ថភាពមន្ត្រីត្រួតពិនិត្យ ........................................................................ ២៥
៤.២. កិច្ចសហប្រតិបត្តិការអន្តរជាតិ ........................................................................ ២៦
**បញ្ជីឧបសម្ព័ន្ធ** ........................................................................ ២៧

# បញ្ជីរូបភាព និងតារាង

## រូបភាព

រូបភាព ១: រចនាសម្ព័ន្ធប្រព័ន្ធធនាគារនៅកម្ពុជា........................................................................ ១
រូបភាព ២: ធនាគារ-ចំនួនអ្នកខ្ចីប្រាក់និងអ្នកដាក់ប្រាក់បញ្ញើ ....................................................... ៥
រូបភាព ៣: ធនាគារ-ឥណទាននិងប្រាក់បញ្ញើអតិថិជន.................................................................. ៥
រូបភាព ៤: ធនាគារ-ឥណទានតាមវិស័យសេដ្ឋកិច្ច.................................................................... ៦
រូបភាព ៥: ធនាគារ-អនុបាតឥណទានមិនដំណើរការ.................................................................. ៦
រូបភាព ៦: មីក្រូហិរញ្ញវត្ថុ-កំណើនទ្រព្យសកម្ម........................................................................ ៧
រូបភាព ៧: មីក្រូហិរញ្ញវត្ថុ-ឥណទានតាមវិស័យសេដ្ឋកិច្ច ........................................................... ៧
រូបភាព ៨: មីក្រូហិរញ្ញវត្ថុ-ឥណទាននិងប្រាក់បញ្ញើ..................................................................... ៧
រូបភាព ៩: មីក្រូហិរញ្ញវត្ថុ-គុណភាពសំពៀតឥណទាន................................................................. ៧
រូបភាព ១០: លំហូរចូលនៃការវិនិយោគផ្ទាល់បរទេសក្នុងវិស័យអចលនទ្រព្យនៅកម្ពុជា................. ២២
រូបភាព ១១: ចំណែកទីផ្សារឥណទានទៅវិស័យអចលនទ្រព្យ
របស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ....................................................................... ២៣
រូបភាព ១២: ឥណទានទៅវិស័យអចលនទ្រព្យ........................................................................ ២៣

## តារាង

តារាង ១: បណ្តាញព័ត៌មានរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុពីឆ្នាំ២០១៣-២០១៧.................. ២
តារាង ២: ចំណែកទីផ្សារនៃគ្រឹះស្ថានធនាគារតាមប្រភេទភាគទុនិក ........................................... ៤
តារាង ៣: ការវិវឌ្ឍន៍ក្នុងវិស័យធនាគារ (កំណើនឆ្នាំលើឆ្នាំ) ......................................................... ៥
តារាង ៤: វិស័យភតិសន្យាហិរញ្ញវត្ថុ........................................................................................ ៩
តារាង ៥: លំហូរវិនិយោគក្នុងវិស័យអចលនទ្រព្យនៅកម្ពុជា ......................................................២២

## ទិន្នន័យទាំងអស់មិនទាន់ត្រូវបានធ្វើសវនកម្ម
## និងត្រូវបានរាយការណ៍ដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

## ១. ការអភិវឌ្ឍសំខាន់ៗនៃវិស័យធនាគារ

### ១.១. និន្នាការទូទៅនៃគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ស្របនឹងការរីកចម្រើននៃសេដ្ឋកិច្ច វិស័យធនាគារក៏បានពង្រីកនូវប្រតិបត្តិការរបស់ខ្លួនផងដែរ ដើម្បីឆ្លើយតបទៅនឹងបរិការណ៍នេះដូចជា ការបើកសាខាធនាគារបរទេសថ្មីៗលំដាប់ពិភពលោក។ គិតត្រឹមដំណាច់ឆ្នាំ២០១៧នេះ ប្រព័ន្ធធនាគារកម្ពុជា រួមមាន ធនាគារពាណិជ្ជ ៣៩ (សាខាធនាគារបរទេស ១២ ធនាគារក្នុងស្រុក ១២ និងបុត្តសម្ព័ន្ធធនាគារ ១៥) ធនាគារឯកទេស ១៥ (ធនាគាររដ្ឋ ១) គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើពីសាធារណជន ៧ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ៦៩ គ្រឹះស្ថានឥណទានជនបទ ៣១៣ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ១១ អ្នកដំណើរការតតិយភាគី ៦ គ្រឹះស្ថានផ្តល់សេវាទូទាត់ ៩ ក្រុមហ៊ុនក្រេឌីតប្យូរ៉ូកម្ពុជា ១ ការិយាល័យតំណាងធនាគារបរទេស ៦ និងអាជីវកម្មប្តូរប្រាក់ ២.៤៧៨ (រូបភាព ១)។

**រូបភាព១: រចនាសម្ព័ន្ធប្រព័ន្ធធនាគារនៅកម្ពុជា**




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

### តារាង១: បណ្តាញព័ត៌មានរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ[1] ពីឆ្នាំ២០១៣-២០១៧

| គ្រឹះស្ថានធនាគារ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ |
|---|---|---|---|---|---|
| **ធនាគារពាណិជ្ជ** | | | | | |
| **ធនាគារក្នុងស្រុក–ភាគទុនិកភាគច្រើនជាអ្នកក្នុងស្រុក** | | | | | |
| ចំនួនធនាគារ | ៦ | ៧ | ៧ | ៧ | ៧ |
| ចំនួនសាខានិងទីស្នាក់ការកណ្តាល | ៣១០ | ៣៥៤ | ៣៧៥ | ៣៨៣ | ៣៩៥ |
| ចំនួនបុគ្គលិក | ១១.៧៩៣ | ១៤.៨៩៦ | ១៦.២៣៩ | ១៧.០២៣ | ១៧.៦២៨ |
| ចំនួនទីតាំងម៉ាស៊ីន ATM | ៣២៧ | ៤៥៤ | ៥៤៤ | ៥៧៤ | ៧១២ |
| **ធនាគារក្នុងស្រុក–ភាគទុនិកភាគច្រើនជាជនបរទេស** | | | | | |
| ចំនួនធនាគារ | ៥ | ៦ | ៥ | ៥ | ៥ |
| ចំនួនសាខានិងទីស្នាក់ការកណ្តាល | ៣៣ | ៤៧ | ៥៤ | ២២៥ | ២៤៤ |
| ចំនួនបុគ្គលិក | ១.០០០ | ១.៤៤៤ | ១.៧៣៨ | ៦.៣៨២ | ៧.៦០៧ |
| ចំនួនទីតាំងម៉ាស៊ីន ATM | ៧៧ | ១១៧ | ១៧៥ | ២៧៦ | ៣៥២ |
| **ធនាគារបុត្តសម្ព័ន្ធបរទេស** | | | | | |
| ចំនួនធនាគារ | ១៤ | ១២ | ១៤ | ១៤ | ១៥ |
| ចំនួនសាខានិងទីស្នាក់ការកណ្តាល | ១២៨ | ១១៩ | ១៤២ | ១៥០ | ១៥៧ |
| ចំនួនបុគ្គលិក | ៣.០៦៧ | ២.៩៨៤ | ៣.៥២៩ | ៣.៦៣៤ | ៤.០០២ |
| ចំនួនទីតាំងម៉ាស៊ីន ATM | ៣៦០ | ៣៥៨ | ៣៩១ | ៣៩៧ | ៤០៩ |
| **ធនាគារសាខាបរទេស** | | | | | |
| ចំនួនធនាគារ | ១០ | ១១ | ១០ | ១១ | ១២ |
| ចំនួនសាខានិងទីស្នាក់ការកណ្តាល | ១៦ | ២១ | ២២ | ២៥ | ៣១ |
| ចំនួនបុគ្គលិក | ៣៦១ | ៤៣៩ | ៤៦៣ | ៥៣០ | ៦២៦ |
| ចំនួនទីតាំងម៉ាស៊ីន ATM | ២ | ៦ | ៨ | ១៣ | ១៧ |
| **ចំនួនសរុបធនាគារពាណិជ្ជ** | | | | | |
| ចំនួនសរុបធនាគារ | ៣៥ | ៣៦ | ៣៦ | ៣៧ | ៣៩ |
| ចំនួនសាខានិងទីស្នាក់ការកណ្តាលសរុប | ៤៨៧ | ៥៤១ | ៥៩៣ | ៧៨៣ | ៨២៧ |
| ចំនួនសរុបបុគ្គលិក | ១៦.២២១ | ១៩.៧៦៣ | ២១.៩៦៩ | ២៧.៥៦៩ | ២៩.៨៦៣ |
| ចំនួនសរុបទីតាំងម៉ាស៊ីន ATM | ៧៦៦ | ៩៤០ | ១.១១៤ | ១.២៦០ | ១.៥៩០ |
| **ធនាគារឯកទេស** | | | | | |
| **ធនាគារឯកទេសរបស់រដ្ឋ** | | | | | |
| ចំនួនធនាគារ | ១ | ១ | ១ | ១ | ១ |
| ចំនួនសាខានិងទីស្នាក់ការកណ្តាល | ១ | ១ | ១ | ១ | ១ |
| ចំនួនបុគ្គលិក | ៥៩ | ៦៧ | ៧៥ | ៨៩ | ៩៣ |
| **ធនាគារឯកទេស–ភាគទុនិកភាគច្រើនជាអ្នកក្នុងស្រុក** | | | | | |
| ចំនួនធនាគារ | ៤ | ៤ | ៣ | ៥ | ៥ |
| ចំនួនសាខានិងទីស្នាក់ការកណ្តាល | ៦ | ៧ | ៧ | ១០ | ១០ |
| ចំនួនបុគ្គលិក | ២៤៣ | ១៧៨ | ៤០៧ | ៥១៨ | ៥១០ |

[1] តួលេខទាំងនេះ បានមកពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលមាននៅក្នុងឧបសម្ព័ន្ធទី៤

| | | | | | |
|---|---|---|---|---|---|
| **ធនាគារឯកទេស–ភាគទុនិកភាគច្រើនជាជនបរទេស** | | | | | |
| ចំនួនធនាគារ | ៣ | ៦ | ៧ | ៩ | ៩ |
| ចំនួនសាខានិងទីស្នាក់ការកណ្តាល | ៣ | ៨ | ១៣ | ១៨ | ១៨ |
| ចំនួនបុគ្គលិក | ៤៥ | ២៦៥ | ៣៨១ | ៨៦២ | ៩៧៩ |
| **ចំនួនសរុបធនាគារឯកទេស** | | | | | |
| ចំនួនសរុបធនាគារ | ៨ | ១១ | ១១ | ១៥ | ១៥ |
| ចំនួនសាខានិងទីស្នាក់ការកណ្តាលសរុប | ១០ | ១៦ | ២១ | ២៩ | ២៩ |
| ចំនួនសរុបបុគ្គលិក | ៣៤៧ | ៥១០ | ៨៦៣ | ១.៤៦៩ | ១.៥៨២ |
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ | | | | | |
| **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ** | | | | | |
| ចំនួនគ្រឹះស្ថាន | ៧ | ៧ | ៨ | ៧ | ៧ |
| ចំនួនសាខានិងទីស្នាក់ការកណ្តាល | ១.២៧៩ | ១.៣៨៣ | ១.៦៣២ | ១.៤៥៦ | ៩៤៦ |
| ចំនួនបុគ្គលិក | ១២.៨៤២ | ១៥.៥៧៦ | ២០.៨០៨ | ១៩.៩៨៧ | ២១.៦៧១ |
| ចំនួនទីតាំងម៉ាស៊ីន ATM | ៧៣ | ១៩៧ | ២៩៨ | ៣០៧ | ៣៥០ |
| **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ** | | | | | |
| ចំនួនគ្រឹះស្ថាន | ២៩ | ៣២ | ៥០ | ៦៤ | ៦៩ |
| ចំនួនសាខានិងទីស្នាក់ការកណ្តាល | ៩៣៧ | ១.៣១១ | ២.១៨៦ | ២.៦៩៨ | ៨៧១ |
| ចំនួនបុគ្គលិក | ២.៩៦៤ | ៤.០១៤ | ៥.៤៦០ | ៦.៥៨១ | ៦.៦៣១ |
| **ចំនួនគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ** | | | | | |
| ចំនួនសរុបគ្រឹះស្ថាន | ៣៦ | ៣៩ | ៥៨ | ៧១ | ៧៦ |
| ចំនួនសាខានិងទីស្នាក់ការកណ្តាលសរុប | ២.២១៦ | ២.៦៩៤ | ៣.៨១៨ | ៤.១៥៤ | ១.៨១៧ |
| ចំនួនសរុបបុគ្គលិក | ១៥.៨០៦ | ១៩.៥៩០ | ២៦.២៦៨ | ២៦.៥៦៨ | ២៨.៣០២ |
| ចំនួនសរុបទីតាំងម៉ាស៊ីន ATM | ៧៣ | ១៩៧ | ២៩៨ | ៣០៧ | ៣៥០ |
| គ្រឹះស្ថានឥណទានជនបទ | | | | | |
| **ចំនួនសរុបគ្រឹះស្ថាន** | **៣៥** | **៣៨** | **១០៩** | **១៧០** | **៣១៣** |
| **ចំនួនសរុបបណ្តាញប្រតិបត្តិការ** | **៨៤៣** | **៥០៩** | **១.៧១៥** | **២.០៨៣** | **៣.៣៦៦** |
| **ចំនួនសរុបបុគ្គលិក** | **៨៩៧** | **៩៤២** | **៣.២៥៥** | **៣.៦៧០** | **៥.១២៣** |
| ក្រុមហ៊ុនភតិសន្យា | | | | | |
| ចំនួនសរុបក្រុមហ៊ុន | ២ | ៦ | ៩ | ១២ | ១១ |
| **ការិយាល័យតំណាងធនាគារបរទេស** | | | | | |
| ចំនួនសរុបការិយាល័យ | ៦ | ៧ | ៨ | ៧ | ៦ |
| **ការិយាល័យក្រេឌីតប្យូរ៉ូ** | | | | | |
| ចំនួនសរុបក្រុមហ៊ុន | ១ | ១ | ១ | ១ | ១ |

ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

**តារាង២: ចំណែកទីផ្សារនៃគ្រឹះស្ថានធនាគារតាមប្រភេទភាគទុនិក**

| ចំណែកទីផ្សារ | ទ្រព្យសកម្ម | | ឥណទាន | | ប្រាក់បញ្ញើ | | ដើមទុន | |
|---|---|---|---|---|---|---|---|---|
| | ធ្នូ-១៦ | ធ្នូ-១៧ | ធ្នូ-១៦ | ធ្នូ-១៧ | ធ្នូ-១៦ | ធ្នូ-១៧ | ធ្នូ-១៦ | ធ្នូ-១៧ |
| **ធនាគារពាណិជ្ជ** | | | | | | | | |
| ធនាគារបរទេស | ៥៥,៧៤% | ៥៥,៤១% | ៥៣,៧៤% | ៥៥,០៨% | ៥៣,២១% | ៥២,៧៨% | ៥៨,៧៩% | ៦២,៤៦% |
| ធនាគារក្នុងស្រុក | ៤២,៤១% | ៤២,៦១% | ៤៤,០៥% | ៤២,៥៥% | ៤៦,៧៨% | ៤៧,២១% | ៣១,៤៨% | ២៩,៦៧% |
| **ធនាគារឯកទេស** | | | | | | | | |
| ធនាគារបរទេស | ១,០៥% | ១,០៥% | ១,៤៩% | ១,៣២% | ០,០០% | ០,០០% | ៥,៥៥% | ៤,១០% |
| ធនាគារក្នុងស្រុក | ០,៧៩% | ០,៩២% | ០,៧២% | ១,០៥% | ០,០១% | ០,០១% | ៤,១៨% | ៣,៧៧% |
| **សរុប** | | | | | | | | |
| ធនាគារបរទេស | ៥៦,៧៩% | ៥៦,៤៦% | ៥៥,២៣% | ៥៦,៤០% | ៥៣,២១% | ៥២,៧៨% | ៦៤,៣៣% | ៦៦,៥៦% |
| ធនាគារក្នុងស្រុក | ៤៣,២១% | ៤៣,៥៤% | ៤៤,៧៧% | ៤៣,៦០% | ៤៦,៧៩% | ៤៧,២២% | ៣៥,៦៧% | ៣៣,៤៤% |
| **សរុប** | **១០០%** | **១០០%** | **១០០%** | **១០០%** | **១០០%** | **១០០%** | **១០០%** | **១០០%** |

ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

## ១.២. ស្ថានភាព និងប្រតិបត្តិការហិរញ្ញវត្ថុ

### ១.២.១. ប្រតិបត្តិការនៃវិស័យធនាគារ

ប្រតិបត្តិការនៃវិស័យធនាគារបន្តរីកលូតលាស់ទាំងទំហំនិងវិសាលភាព និងកាន់តែមានភាពប្រទាក់ក្រឡាជាងមុន ព្រមទាំងដើរតួនាទីយ៉ាងសំខាន់នៅក្នុងប្រព័ន្ធហិរញ្ញវត្ថុកម្ពុជា។ ទ្រព្យសកម្មនិងឥណទានសរុបរបស់គ្រឹះស្ថានធនាគារកើនឡើងដល់ ១១៥.៥៧៧,៤ ប៊ីលានរៀល និង ៦៦.៣៧៩,៩ ប៊ីលានរៀល ស្មើនឹង ១៤២,០២% និង ៨០,៧% នៃផលិតផលក្នុងស្រុកសរុបរៀងគ្នា។ កំណើនឥណទាននិងប្រាក់បញ្ញើរបស់គ្រឹះស្ថានធនាគារបន្តកើនឡើងជាបន្តបន្ទាប់។ គិតត្រឹមដំណាច់ឆ្នាំ២០១៧ កំណើនឥណទានរបស់ធនាគារមានកម្រិត ១៧,២១% ទាបជាងឆ្នាំ២០១៦។ ឥណទាននៅតែបន្តប្រមូលផ្តុំលើវិស័យសំខាន់ៗក្នុងសេដ្ឋកិច្ច មានដូចជា ការជួញដូររាយនិងដុំ (៣០%) កសិកម្ម (១០,៤%) សំណង់ (៩,៥%) និងទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន (៩,៣%) និងវិស័យផ្សេងៗ (៤០,៨%)។ គិតត្រឹមដំណាច់ខែធ្នូ ឆ្នាំ២០១៧ កំណើនប្រាក់បញ្ញើរបស់ធនាគារមានកម្រិត ២៥,១%។ គ្រឹះស្ថានធនាគារបន្តកេណ្ឌប្រមូលប្រាក់បញ្ញើពីសាធារណជនកាន់តែច្រើន ដែលឆ្លុះបញ្ចាំងតាមរយៈកំណើននៃប្រាក់បញ្ញើអតិថិជនកាន់តែច្រើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ដែលនេះក៏ឆ្លុះបញ្ចាំងពីការកើនឡើងនូវជំនឿទុកចិត្តរបស់សាធារណជនមកលើប្រព័ន្ធធនាគារកម្ពុជា តាមរយៈកិច្ចខិតខំប្រឹងប្រែងរបស់ធនាគារជាតិនៃកម្ពុជាលើការបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុក្នុងស្រទាប់ប្រជាជន។ ប្រាក់បញ្ញើអតិថិជននៅធនាគារបន្តកើនឡើងដល់ ៦៩.៦៨៤,៤ ប៊ីលានរៀល ដែលក្នុងនោះ ៩២,៤% នៃប្រាក់បញ្ញើអតិថិជនគឺជាប្រាក់

បញ្ញើជុំ។ ជាមួយគ្នានេះ ចំនួនអ្នកដាក់ប្រាក់បញ្ញើកើនដល់ ៣.៤៨២.២៧៧ នាក់ ដែល ៩១,៧% នៃអ្នកដាក់ប្រាក់បញ្ញើជាស្រ្តី និងភាគច្រើននៃអ្នកដាក់ប្រាក់បញ្ញើ រួមមាន ឯកត្តជន (៥៣,៨%) សហគ្រាសអាជីវកម្ម (២៣,៩%) គ្រឹះស្ថានធនាគារក្នុងស្រុកនិងក្រៅប្រទេស (១០%) និងគ្រឹះស្ថានផ្សេងៗ (១៤,៦%)។

**តារាង៣: ការវិវឌ្ឍន៍ក្នុងវិស័យធនាគារ (កំណើនឆ្នាំលើឆ្នាំ)**

| ការវិវត្តក្នុងវិស័យធនាគារ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ |
|---|---|---|---|---|---|
| កំណើនទ្រព្យសកម្ម | ១៦,៩០% | ២៧,១០% | ២៣,២១% | ២០,៩០% | ២០,១២% |
| កំណើនឥណទាន | ២៥,៧៦% | ២៧,១១% | ២៥,៦៥% | ២០,៥២% | ១៧,២១% |
| កំណើនប្រាក់បញ្ញើ | ១២,២៤% | ២៤,៩៥% | ១៧,៣៨% | ២១,៨២% | ២៥,១១% |
| ទ្រព្យសកម្មធៀបផ.ស.ស | ៨២,៧៨% | ៩៨,៣៣% | ១០៧,៨៩% | ១១៨,២៣% | ១៩២,០២% |
| ឥណទានធៀបផ.ស.ស | ៤៧,៧៤% | ៥៦,៧១% | ៦៣,៤៦% | ៦៨,៨៣% | ៨០,៦៨% |
| ប្រាក់បញ្ញើធៀបផ.ស.ស | ៤៩,០៩% | ៥៩,១៦% | ៦១,៨៥% | ៦៨,៤៤% | ៨៥,៦៣% |

ប្រភព ៖ ការគណនារបស់មន្រ្តីធនាគារជាតិនៃកម្ពុជា

ការកើនឡើងនូវទំហំប្រតិបត្តិការបានជំរុញឱ្យគ្រឹះស្ថានធនាគារបន្តពង្រីកបណ្តាញប្រតិបត្តិការរបស់ខ្លួនកាន់តែច្រើនជាងមុន តាមរយៈការបើកសាខាថ្មីបន្ថែមចំនួន ៤៤ និងដាក់ឱ្យប្រើប្រាស់នូវម៉ាស៊ីនអេធីអឹម (ATM) ថ្មី ចំនួន ២៧៣ ម៉ាស៊ីន បន្ថែមពីលើសាខានិងម៉ាស៊ីនអេធីអឹមដែលកំពុងដំណើរការនាពេលបច្ចុប្បន្ន។ ការប្រើប្រាស់បណ្ណឥណទាននិងបណ្ណឥណពន្ធសម្រាប់ការទូទាត់ទូទៅត្រូវបានសង្កេតឃើញថា មានការកើនឡើងគួរឱ្យកត់សម្គាល់ ស្របពេលដែលចំនួនអ្នកប្រើប្រាស់សេវាធនាគារក៏បានកើនឡើងផងដែរ។ គិតត្រឹមដំណាច់ឆ្នាំ២០១៧ ចំនួនបណ្ណឥណទាននិងបណ្ណឥណពន្ធកើនឡើងដល់ ៧៤.១៣០ និង ១.៨១៣.៨៣៥ រៀងគ្នា។

**រូបភាព២: ធនាគារ-ចំនួនអ្នកខ្ចីប្រាក់ និងអ្នកដាក់ប្រាក់បញ្ញើ**




**រូបភាព៣: ធនាគារ-ឥណទាន និងប្រាក់បញ្ញើអតិថិជន**




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

**រូបភាព៤: ធនាគារ-ឥណទានតាមវិស័យសេដ្ឋកិច្ច**




**រូបភាព៥: ធនាគារ-អនុបាតឥណទានមិនដំណើរការ**




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

អនុបាតឥណទានមិនដំណើរការរបស់វិស័យធនាគារនៅរក្សាបានក្នុងកម្រិត ២,៤%។ អនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្មមានចំនួន ១,៥៤% រីឯអនុបាតប្រាក់ចំណេញធៀបនឹងដើមទុនមានចំនួន ៨,៤%។ ធនាគារជាតិនៃកម្ពុជាបន្តយកចិត្តទុកដាក់ខ្ពស់លើការត្រួតពិនិត្យប្រតិបត្តិការគ្រឹះស្ថានធនាគារ ដើម្បីរក្សាឱ្យបាននូវគុណភាពទ្រព្យសកម្ម ជាពិសេសធានាបាននូវភាពរឹងមាំ និងសុវត្ថិភាពរបស់ប្រព័ន្ធធនាគារទាំងមូល។ ការដាក់ចេញនូវប្រកាសស្តីពី ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមភែរមិន របស់ធនាគារជាតិនៃកម្ពុជា កាលពីថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៧ នឹងជួយពង្រឹងការអនុវត្តក្របខ័ណ្ឌគ្រប់គ្រងហានិភ័យឥណទានដោយប្រុងប្រយ័ត្ន និងគ្រប់ជ្រុងជ្រោយ។

### ១.២.២. ប្រតិបត្តិការនៃវិស័យមីក្រូហិរញ្ញវត្ថុ

វិស័យមីក្រូហិរញ្ញវត្ថុកម្ពុជាបាននិងកំពុងបន្តរីកចម្រើនគួរឱ្យកត់សម្គាល់ តាមរយៈការធ្វើពិពិធកម្មសេវាកម្មហិរញ្ញវត្ថុបន្ថែមទៀត លើសេវាផ្តល់ឥណទាននិងសេវាប្រាក់សន្សំ និងការពង្រីកការផ្តល់សេវាផ្ទេរប្រាក់ សេវាធនាគារចល័ត សេវាណែនាំធានារ៉ាប់រងខ្នាតតូច និងសេវាម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិបន្ថែមទៀត។ ទន្ទឹមនឹងនេះ វិស័យមីក្រូហិរញ្ញវត្ថុក៏បានចូលរួមចំណែកក្នុងការលើកស្ទួយកម្រិតជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋឱ្យមានភាពប្រសើរឡើង តាមរយៈការពង្រីកដែនសេវាកម្មរបស់ខ្លួននៅតាមទីជនបទ និងការផ្តល់ការងារធ្វើជូនដល់ប្រជាជននៅក្នុងវិស័យនេះ។ ក្នុងឆ្នាំ២០១៧ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានធ្វើប្រតិបត្តិការគ្របដណ្តប់ទូទាំង ២៥ ខេត្ត-ក្រុង ដោយមានការិយាល័យនៅរាជធានីភ្នំពេញចំនួន ៧៦ នៅថ្នាក់ខេត្ត-ក្រុងចំនួន ៣៦៦ និងនៅថ្នាក់ស្រុកចំនួន ៩៧៥ និងបានផ្តល់ការងារដល់បុគ្គលិកចំនួន ២៨.៣០២ នាក់ ក្នុងនោះស្ត្រីមានចំនួន ៧.៩៨៦ នាក់។

**រូបភាព១៦: មីក្រូហិរញ្ញវត្ថុ-កំណើនទ្រព្យសកម្ម**




**រូបភាព១៧: មីក្រូហិរញ្ញវត្ថុ-ឥណទានតាមវិស័យសេដ្ឋកិច្ច**




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

ក្នុងឆ្នាំ២០១៧ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានចំនួនសរុប ៧៦ ដែលក្នុងនោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើមានចំនួន ៧ មានទ្រព្យសកម្មសរុបចំនួន ២០.៣១០,០២ ប៊ីលានរៀល ស្មើនឹង ២៥% នៃផលិតផលក្នុងស្រុកសរុប (ផសស) និងមានកំណើនធៀបឆ្នាំលើឆ្នាំស្មើនឹង ៣០,៥%។ ស្របនឹងការកើនឡើងនូវចំនួនគ្រឹះស្ថាននិងកំណើនទ្រព្យសកម្ម ប្រាក់បញ្ញើរបស់សាធារណជនក្នុងវិស័យមីក្រូហិរញ្ញវត្ថុបានកើនឡើង ៣៤,៣% ដល់ ៨.០០៧,១១ ប៊ីលានរៀល ហើយការផ្តល់ឥណទានបានកើនឡើង ៣៦,១% ដល់ ១៧.២៣៦,៨៤ ប៊ីលានរៀល។ កំណើននៃទ្រព្យសកម្មនិងឥណទានបានឆ្លុះបញ្ចាំងពីកិច្ចគាំទ្រនៃវិស័យមីក្រូហិរញ្ញវត្ថុដល់សេដ្ឋកិច្ចគ្រួសាររបស់ប្រជាពលរដ្ឋនៅតាមតំបន់ជនបទ និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ទន្ទឹមនេះ ចំនួនអ្នកដាក់ប្រាក់បញ្ញើមាន ១,៨ លានគណនី និងចំនួនអ្នកខ្ចីប្រាក់ ១,៨ លានគណនី។ ជាក់ស្តែង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានផ្តល់ឥណទានទៅកាន់វិស័យសំខាន់ៗ រួមមាន ក្រុមគ្រួសារ ៣៣,៨% កសិកម្ម ២៥,៥% ការជួញដូរនិងពាណិជ្ជកម្ម ១៨,៨% សេវាកម្ម ១០,៤% សំណង់និងដឹកជញ្ជូន ៨,៦% និងផ្សេងៗ ២,២%។

**រូបភាព១៨: មីក្រូហិរញ្ញវត្ថុ-ឥណទាននិងប្រាក់បញ្ញើ**




**រូបភាព១៩: មីក្រូហិរញ្ញវត្ថុ-គុណភាពសំពៀតឥណទាន**




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

កម្រិតអនុបាតឥណទានមិនដំណើរការមានចំនួន ២,១% ក្នុងឆ្នាំ២០១៧ ហើយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបន្តគោរពបានតាមបទប្បញ្ញត្តិប្រុងប្រយ័ត្ន ដោយបានរក្សានូវអនុបាតសាធនភាពនិងអនុបាតសន្ទនីយភាពក្នុងកម្រិត ២០,៦៨% និង ២០៨,២៣% រៀងគ្នា ខ្ពស់ជាងកម្រិតអប្បបរមា ១៥% និង ៧០% ដែលបានកំណត់ដោយបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា។ អនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្មនិងអនុបាតប្រាក់ចំណេញធៀបនឹងដើមទុនមានកម្រិត ២,៧១% និង ១២,៧៨% រៀងគ្នា។

សមិទ្ធផលរីកចម្រើននៃវិស័យមីក្រូហិរញ្ញវត្ថុ កើតឡើងតាមរយៈការពង្រឹងអភិបាលកិច្ចល្អ ការគោរពគោលការណ៍កិច្ចការពារអតិថិជន និងតម្លាភាព ការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងការពង្រឹងកិច្ចសហប្រតិបត្តិការល្អរវាងអាជ្ញាធរអាណាព្យាបាល ជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ព្រមទាំងការបង្កើតគោលនយោបាយលើកទឹកចិត្តរបស់រាជរដ្ឋាភិបាលផងដែរ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើបាននិងកំពុងប្រកួតប្រជែងក្នុងការកេណ្ឌប្រមូលប្រភពទុនក្នុងស្រុក ដើម្បីពង្រីកទំហំនិងវិសាលភាពប្រតិបត្តិការរបស់ខ្លួន តាមរយៈការផ្តល់អត្រាការប្រាក់បញ្ញើខ្ពស់ ដែលធ្វើឱ្យអត្រាការប្រាក់បញ្ញើបន្តមានស្ថិរភាពក្នុងកម្រិតជាមធ្យមប្រមាណ ៥,៦% សម្រាប់ប្រាក់រៀល និង ៤,៨% សម្រាប់ប្រាក់ដុល្លារអាមេរិក។ ទន្ទឹមនេះ ការបញ្ចេញឥណទានថ្មីៗរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ត្រូវបានគិតជាមួយអត្រាការប្រាក់មិនលើសពីកម្រិតកំណត់របស់ធនាគារជាតិនៃកម្ពុជា ១៨% ក្នុងមួយឆ្នាំ ចាប់ពីខែមេសា ឆ្នាំ២០១៧។ ការកំណត់ពិដានឥណទានក្នុងវិស័យមីក្រូហិរញ្ញវត្ថុ បានជំរុញឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបង្កើនការយកចិត្តទុកដាក់ និងពង្រឹងប្រសិទ្ធភាពលើប្រតិបត្តិការឥណទាន ដែលឆ្លុះបញ្ចាំងតាមរយៈការធ្លាក់ចុះជាបន្តបន្ទាប់នៃចំណាយប្រតិបត្តិការ ការថយចុះនៃអនុបាតឥណទានមិនដំណើរការ និងការកេណ្ឌប្រមូលប្រាក់បញ្ញើក្នុងស្រុក។ ទោះបីជាគម្លាតអត្រាការប្រាក់រវាងប្រាក់បញ្ញើនិងឥណទាននៅមានកម្រិតខ្ពស់នៅឡើយ ប៉ុន្តែគម្លាតនេះមាននិន្នាការថយចុះ។ គម្លាតអត្រាការប្រាក់បង្ហាញពីលទ្ធភាពខ្ពស់ក្នុងការរកប្រាក់ចំណេញក្នុងវិស័យនេះ ដែលអាចផ្តល់លទ្ធភាពឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបន្តពង្រីកបណ្តាញប្រតិបត្តិការបន្ថែមទៀត ដើម្បីផ្តល់សេវាហិរញ្ញវត្ថុដល់ប្រជាជននៅទីជនបទ ដែលមិនទាន់ទទួលបានសេវាហិរញ្ញវត្ថុផ្លូវការនៅឡើយ។

ជារួម ទោះបីជាមានបញ្ហាប្រឈមថ្មីៗមួយចំនួនក៏ដោយ វិស័យមីក្រូហិរញ្ញវត្ថុកម្ពុជានៅតែបន្តមានការរីកចម្រើន និងទទួលបានជំនឿទុកចិត្តពីសាធារណជនជាបន្តបន្ទាប់។

### ១.២.៣. ប្រតិបត្តិការនៃវិស័យភតិសន្យាហិរញ្ញវត្ថុ

វិស័យភតិសន្យាហិរញ្ញវត្ថុគឺជាវិស័យមួយថ្មី ប៉ុន្តែមានការរីកចម្រើនគួរឱ្យកត់សម្គាល់ តាមរយៈការបង្កើនសេវាភតិសន្យាហិរញ្ញវត្ថុនេះលើចលនទ្រព្យ ដូចជា ម៉ូតូ រថយន្ត គ្រឿងយន្តប្រើប្រាស់ក្នុងវិស័យកសិកម្ម គ្រឿងចក្រសាងសង់ គ្រឿងអេឡិចត្រូនិក គ្រឿងសង្ហារឹម សម្ភារប្រើប្រាស់ក្នុងគ្រួសារ និងចលនវត្ថុផ្សេងៗទៀតដល់អតិថិជន។ នៅក្នុងឆ្នាំ២០១៧ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុមានចំនួន ១១

មានទ្រព្យសកម្មសរុបបានកើនឡើងដល់ ៧០៧,៩ ប៊ីលានរៀល និងភតិសន្យាហិរញ្ញវត្ថុសរុបកើនឡើងដល់ ៥២៥,៣ ប៊ីលានរៀល ដែលសេវាភតិសន្យាហិរញ្ញវត្ថុទាំងនេះត្រូវបានផ្តល់ដល់អតិថិជនចំនួន ៦៤.២៥២ គណនី។ សេវាភតិសន្យាហិរញ្ញវត្ថុត្រូវបានបែងចែកទៅវិស័យសំខាន់ៗ ដូចជា វិស័យកសិកម្ម ២០% ក្រុមគ្រួសារ ៤២% សំណង់ ៨% ពាណិជ្ជកម្ម ៥% មធ្យោបាយធ្វើដំណើរ ៥% សេវាកម្ម ២% និងផ្សេងៗ ១៩%។ តម្រូវការប្រើប្រាស់របស់អតិថិជនបានជំរុញឱ្យទីផ្សារភតិសន្យាហិរញ្ញវត្ថុទទួលបានការចាប់អារម្មណ៍កាន់តែខ្លាំងពីវិនិយោគិនទាំងក្នុងស្រុកនិងក្រៅប្រទេស។

**តារាង៤: វិស័យភតិសន្យាហិរញ្ញវត្ថុ** (គិតជាប៊ីលានរៀល)

| ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ |
|---|---|---|---|---|---|
| ចំនួនទ្រព្យសកម្មសរុប | ៣៧,៤៤ | ១៨៦,៣៣ | ៤១០,៣៥ | ៦២២,៨១ | ៧០៧,៩៥ |
| ចំនួនឥណទានសរុប | ១៦,៤០ | ១៤៧,០៦ | ៣៤៤,៩៧ | ៤៨៥,០៤ | ៥២៥,៣៤ |
| ឥណទានមិនដំណើរការ | 0% | ៣,១៦% | ៥,៣១% | ៥,៩៣% | ៥,២៩% |
| មូលនិធិផ្ទាល់សុទ្ធ | ៧,៨៩ | ៣៤,៣៦ | ៤៤,០៤ | ១១៣,២៧ | ១៧៣,៤៦ |
| ចំនួនបុគ្គលិក (នាក់) | ២១២ | ៥៤៥ | ៨៥៧ | ១,២៤៥ | ១,២៦៦ |
| ចំនួនអតិថិជន (នាក់) | ២,៦៣៨ | ១៨,៦៨៣ | ៤៣,៤១៣ | ៦១,៣៧២ | ៦៤,២៥២ |

ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

### ១.២.៤. ប្រតិបត្តិការនៃអាជីវកម្មប្តូរប្រាក់

ធនាគារជាតិនៃកម្ពុជាបានចេញប្រកាសលេខ ធ៩-០៩-២៣០ ប្រ.ក ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៩ ស្តីពី *"ការផ្តល់អាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតសម្រាប់អាជីវកម្មប្តូរប្រាក់"* ក្នុងគោលបំណងគ្រប់គ្រងរាល់អាជីវកម្មប្តូរប្រាក់ រួមមាន ការទិញនិងលក់ក្រដាសប្រាក់ជារូបិយបណ្ណបរទេស និងការទិញមូលប្បទានបត្រទេសចរណ៍ដែលធ្វើសកម្មភាពក្នុងព្រះរាជាណាចក្រកម្ពុជា។ ចំពោះការប្រកបអាជីវកម្មនាំចេញ-នាំចូលលោហធាតុ និងត្បូងថ្មមានតម្លៃ តម្រូវឱ្យអនុលោមតាមប្រកាសលេខ ធ៩-០៩-២៦២ ប្រ.ក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៩ ស្តីពី *"ការផ្តល់អាជ្ញាបណ្ណប្រកបអាជីវកម្មនាំចេញ-នាំចូលលោហធាតុនិងត្បូងថ្មមានតម្លៃ"*។ បន្ថែមលើនេះ ដើម្បីជំរុញការអនុវត្តឱ្យស្របតាមប្រកាសស្តីពី *"ការផ្តល់អាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតសម្រាប់អាជីវកម្មប្តូរប្រាក់"* កាលពីថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៧ ធនាគារជាតិនៃកម្ពុជាបានចេញសេចក្តីជូនដំណឹងដល់អាជីវករប្តូរប្រាក់ទាំងអស់ ដែលកំពុងធ្វើប្រតិបត្តិការក្នុងប្រទេសកម្ពុជា ត្រូវបំពេញកាតព្វកិច្ចក្នុងការស្នើសុំ ឬបន្តសុពលភាពលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណប្រកបអាជីវកម្មប្តូរប្រាក់ពីធនាគារជាតិនៃកម្ពុជា។ គិតត្រឹមដំណាច់ឆ្នាំ២០១៧ អាជីវករប្តូរប្រាក់មានចំនួនសរុប ២.៤៧៨ ដែលក្នុងនោះអាជ្ញាបណ្ណទៅអាជីវករប្តូរប្រាក់មាន ២៦ អាជ្ញាបណ្ណទៅគ្រឹះស្ថានធនាគារចំនួន ២៥ អាជ្ញាបណ្ណទៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ២៦ និងលិខិតអនុញ្ញាតប្រកបអាជីវកម្មប្តូរប្រាក់ចំនួន ២.៤០១។

### ១.២.៥. ចន្លោះខាងនៃការចារចុះបញ្ជីគ្រឹះស្ថានឥណទានជនបទ

គិតត្រឹមដំណាច់ឆ្នាំ២០១៧ ធនាគារជាតិនៃកម្ពុជាបានផ្តល់វិញ្ញាបនបត្រដល់គ្រឹះស្ថានឥណទានជនបទសរុបចំនួន ៣១៣។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញនូវប្រកាសលេខ ធ៧-០១៧-៣២៦ ប្រ.ក ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ស្តីពីការផ្តល់វិញ្ញាបនបត្រចំពោះគ្រឹះស្ថានឥណទានជនបទ ក្នុងគោលបំណងកំណត់លក្ខខណ្ឌនៃការផ្តល់វិញ្ញាបនបត្រ និងពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងនិងការត្រួតពិនិត្យគ្រឹះស្ថានដែលផ្តល់ឥណទានខ្នាតតូច។

ការចុះបញ្ជីរបស់គ្រឹះស្ថានឥណទានជនបទមានដំណើរការរលូន និងប្រកបដោយប្រសិទ្ធភាព នៅក្រោមកិច្ចសហប្រតិបត្តិការដ៏ល្អរវាងធនាគារជាតិនៃកម្ពុជា ក្រសួងមហាផ្ទៃ ក្រសួងពាណិជ្ជកម្ម និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត។ ដើម្បីទទួលបានការចុះបញ្ជីជាប្រតិបត្តិករឥណទានជនបទ អង្គការសមាគមត្រូវផ្លាស់ប្តូរទម្រង់គតិយុត្តិទៅជាក្រុមហ៊ុនទទួលខុសត្រូវមានកម្រិតវិញ។ ជាមួយគ្នានេះដែរ ធនាគារជាតិនៃកម្ពុជាក៏តម្រូវឱ្យគ្រឹះស្ថានឥណទានជនបទទាំងអស់ ផ្ញើរបាយការណ៍ប្រចាំត្រីមាសនិងចុះត្រួតពិនិត្យដល់ទីកន្លែង ដើម្បីធានាបាននូវប្រសិទ្ធភាពការងារប្រកបដោយតម្លាភាព។

## ២. ការវិវឌ្ឍន៍ក្របខ័ណ្ឌនៃការត្រួតពិនិត្យនិងបទប្បញ្ញត្តិ

### ២.១. ការពិនិត្យឡើងវិញ និងការដាក់ចេញនូវបទប្បញ្ញត្តិ

ក្នុងកិច្ចការពារអតិថិជន និងបង្កើនការត្រួតពិនិត្យនិងតាមដានស្ថានភាពរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាព និងធានាបានភាពរឹងមាំក្នុងប្រព័ន្ធធនាគារ ធនាគារជាតិនៃកម្ពុជាក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យបានដាក់ចេញនូវវិធានសមស្របចំនួន ៩ ក្នុងឆ្នាំ២០១៧ ដើម្បីឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអនុវត្ត។ វិធានទាំងនោះ រួមមាន ៖

១. សេចក្តីជូនដំណឹងលេខ ធ៧-០១៧-១៩៣ ស.ជ.ណ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពី "ការដាក់ស្លាកសញ្ញា "គ្រឹះស្ថានឯកជន" បង្ហាញសាធារណជន"

២. សេចក្តីជូនដំណឹងលេខ ធ៧-០១៧-១៨១ ស.ជ.ណ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពី "ការស្នើសុំប្តូរនិមិត្តសញ្ញារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ"

៣. ប្រកាសលេខ ធ៧-០១៧-១០៩ ប្រ.ក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៧ ស្តីពី "ការកំណត់ពិដានអត្រាការប្រាក់ឥណទាន"

៤. ប្រកាសលេខ ធ៧-០១៧-២៩៩ ប្រ.ក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៧ ស្តីពី "ការដោះស្រាយបណ្តឹងអតិថិជនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ"

៥. ប្រកាសលេខ ធ៧-០១៧-៣០០ ប្រ.ក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៧ ស្តីពី "លក្ខខណ្ឌសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដាក់ពាក្យសុំចុះបញ្ជីលក់មូលបត្រក្នុងផ្សារមូលបត្រកម្ពុជា"

៦. ប្រកាសលេខ ធ៧-០១៧-៣០១ ប្រ.ក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៧ ស្តីពី "ក្របខ័ណ្ឌគ្រប់គ្រងសន្ទនីយភាពរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ"

៧. ប្រកាសលេខ ធ៧-០១៧-៣២៦ ប្រ.ក ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ស្តីពី "ការផ្តល់វិញ្ញាបនបត្រចំពោះគ្រឹះស្ថានឥណទានជនបទ"

៨. ប្រកាសលេខ ធ៧-០១៧-៣៣៥ ប្រ.ក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពី "សវនកម្មចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ"

៩. ប្រកាសលេខ ធ៧-០១៧-៣៨៤ ប្រ.ក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៧ ស្តីពី "ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមភែរមិន"

### ២.១.១. ការដាក់ស្លាកសញ្ញា "គ្រឹះស្ថានឯកជន" បង្ហាញសាធារណជន

ដោយពិនិត្យឃើញថាសាធារណជនមួយចំនួនបានយល់ច្រឡំថា គ្រឹះស្ថានធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថានឥណទានជនបទ ជាគ្រឹះស្ថានរបស់រដ្ឋ ដែលបានបង្កឱ្យមានបាតុភាពអសកម្មមួយចំនួនក្នុងសង្គម ធនាគារជាតិនៃកម្ពុជាកាលពីថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១៧ បានចេញសេចក្តីជូនដំណឹង ស្តីពីការដាក់ស្លាកសញ្ញា "គ្រឹះស្ថានឯកជន" បង្ហាញសាធារណជន ដែលតម្រូវឱ្យគ្រប់គ្រឹះស្ថានទាំងអស់ត្រូវអនុវត្តសកម្មភាពដូចខាងក្រោម ៖

- បន្ថែមនៅលើស្លាកយីហោរបស់ខ្លួននូវពាក្យថា "គ្រឹះស្ថានឯកជន"
- ដាក់បង្ហាញនូវស្លាកសញ្ញា "គ្រឹះស្ថានឯកជន" នៅទីតាំងសមស្របក្នុងស្នាក់ការរបស់ខ្លួនដែលអតិថិជនងាយមើលឃើញ និង
- អប់រំអតិថិជនរបស់ខ្លួនឱ្យយល់ច្បាស់ពីវប្បធម៌ឥណទាន និងថាខ្លួនជាគ្រឹះស្ថានឯកជនមិនមែនជារបស់រដ្ឋ។

### ២.១.២. ការស្នើសុំប្តូរនិមិត្តសញ្ញារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានឥណទានជនបទ

បន្ទាប់ពីពិនិត្យឃើញថា ការប្រើប្រាស់និមិត្តសញ្ញារបស់គ្រឹះស្ថានមួយចំនួនមានលក្ខណៈស្រដៀងគ្នាជាមួយនិមិត្តសញ្ញារបស់ក្រសួង-ស្ថាប័នរដ្ឋដែលកំពុងប្រើប្រាស់ ដូចជា អក្សរ "រ" ឬ "រូបសិង្ហ" ជាដើម ធនាគារជាតិនៃកម្ពុជាបានចេញសេចក្តីជូនដំណឹងដើម្បីជម្រាបជូនគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ ឱ្យប្តូរនិមិត្តសញ្ញាដែលមានលក្ខណៈស្រដៀងគ្នាជាមួយនឹងនិមិត្តសញ្ញារបស់ក្រសួង-ស្ថាប័នរដ្ឋ និងចៀសវាងការប្រើប្រាស់និមិត្តសញ្ញាណាដែលអាចធ្វើឱ្យសាធារណជនយល់ច្រឡំថា ជាគ្រឹះស្ថានរបស់រដ្ឋ។ ការណ៍នេះ គឺដើម្បីចៀសវាងនូវការភាន់ច្រឡំពីសំណាក់សាធារណជនថា គ្រឹះស្ថានទាំងនោះគឺជាគ្រឹះស្ថានរបស់រដ្ឋ ដែលអាចជះឥទ្ធិពលមិនល្អចំពោះគ្រឹះស្ថានដោយសារសាធារណជន ជាពិសេសអ្នកទទួលបានឥណទានពីគ្រឹះស្ថានយល់ថា បើគាត់មិនទូទាត់សងត្រឡប់ក៏មិនមានបញ្ហាដែរ ព្រោះជាគ្រឹះស្ថានរបស់រដ្ឋ ដែលអាចបណ្តាលឱ្យគ្រឹះស្ថាន

រងនូវការខាតបង់ ឬបណ្តាលឱ្យមានហានិភ័យជាប្រព័ន្ធដល់គ្រឹះស្ថានផ្សេងៗទៀត។ គួរបញ្ជាក់ថា គ្រឹះស្ថានឥណទានជនបទត្រូវអនុវត្តតាមច្បាប់និងបទប្បញ្ញត្តិជាធរមានទាំងឡាយ ដែលចេញដោយធនាគារជាតិនៃកម្ពុជា។ ក្នុងករណីដែលមិនអនុវត្តតាម នោះគ្រឹះស្ថានឥណទានជនបទនឹងត្រូវប្រឈមនឹងការដកហូតវិញ្ញាបនបត្រវិញពីអាជ្ញាធរត្រួតពិនិត្យ។

### ២.១.៣. ការកំណត់ពិដានអត្រាការប្រាក់ឥណទាន

ក្នុងគោលដៅការពារអតិថិជនពីការគិតអត្រាការប្រាក់ខ្ពស់ពេក ក៏ដូចជាជំរុញឱ្យការប្រើប្រាស់ឥណទានមានប្រសិទ្ធភាព កាលពីថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៧ ធនាគារជាតិនៃកម្ពុជាបានចេញប្រកាសស្តីពីការកំណត់ពិដានអត្រាការប្រាក់ឥណទាន ដោយតម្រូវឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថានឥណទានជនបទ ដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា កំណត់អត្រាការប្រាក់ឥណទានមិនឱ្យលើសពី ១៨% ក្នុងមួយឆ្នាំ សម្រាប់គ្រប់ឥណប្រតិទាននៃឥណទាន។ ការកំណត់អត្រាការប្រាក់ឥណទាននេះ អនុវត្តចំពោះកិច្ចសន្យាឥណទានថ្មី រួមទាំងឥណទានរៀបចំឡើងវិញនិងបុនហិរញ្ញប្បទាន ដែលតម្រូវឱ្យគ្រឹះស្ថានចាប់អនុវត្តប្រកាសនេះចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០១៧។

### ២.១.៤. ការដោះស្រាយបណ្តឹងអតិថិជនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

កាលពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៧ ធនាគារជាតិនៃកម្ពុជាបានចេញប្រកាសស្តីពីការដោះស្រាយបណ្តឹងអតិថិជនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្នុងគោលដៅលើកកម្ពស់កិច្ចការពារអតិថិជនដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់អតិថិជន ចំពោះការប្រើប្រាស់ផលិតផលនិងសេវារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ តាមរយៈការដោះស្រាយបណ្តឹងឱ្យបានសមស្របនិងមានប្រសិទ្ធភាព។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវទទួលនិងដោះស្រាយបណ្តឹងដែលទទួលបានផ្ទាល់ពីអតិថិជននិង/ឬបុគ្គលតំណាងអតិថិជន រួមទាំងបណ្តឹងអតិថិជនដែលធនាគារជាតិនៃកម្ពុជាទទួលបានរួចបញ្ជូនបន្តទៅគ្រឹះស្ថាន។ អតិថិជនត្រូវដាក់ពាក្យបណ្តឹងដោយផ្ទាល់មាត់និង/ឬជាលាយលក្ខណ៍អក្សរក្នុងរយៈពេល ៦០ ថ្ងៃ បន្ទាប់ពីបានដឹងអំពីបញ្ហាដែលចង់តវ៉ា។ ជាមួយគ្នានេះផងដែរ គ្រឹះស្ថានមិនត្រូវរារាំង ឬរឹតត្បិតសិទ្ធិរបស់អតិថិជនក្នុងការដាក់ពាក្យបណ្តឹង រួមទាំងការយកសោហ៊ុយលើការដាក់ពាក្យ ការដំណើរការ និងការបញ្ចប់បណ្តឹង។

### ២.១.៥. លក្ខខណ្ឌសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដាក់ពាក្យសុំចុះបញ្ជីលក់មូលបត្រក្នុងផ្សារមូលបត្រកម្ពុជា

ដើម្បីផ្តល់លទ្ធភាពដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងការកៀរគរ និងបង្កើនមូលនិធិសម្រាប់ពង្រីកអាជីវកម្ម ក៏ដូចជារួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា ធនាគារជាតិនៃកម្ពុជាបានកំណត់លក្ខខណ្ឌមួយចំនួនចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលមានបំណងចុះបញ្ជីលក់មូលបត្រក្នុងផ្សារមូលបត្រកម្ពុជា ដូចខាងក្រោម ៖

- សុំការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជា
- មានមូលនិធិផ្ទាល់សុទ្ធយ៉ាងតិច ៦០.០០០.០០០.០០០ (ហុកសិបប៊ីលាន) រៀល
- មានស្ថានភាពហិរញ្ញវត្ថុល្អនិងអភិបាលកិច្ចរឹងមាំ តាមរយៈការធ្វើចំណាត់ថ្នាក់ដោយធនាគារជាតិនៃកម្ពុជា ត្រឹមកម្រិតសុវត្ថិភាពចាប់ពី ២ ឆ្នាំឡើងទៅ និង
- អនុវត្តពេញលេញតាមបទប្បញ្ញត្តិប្រុងប្រយ័ត្ននានារបស់ធនាគារជាតិនៃកម្ពុជា។

ជាងនេះទៅទៀត បន្ទាប់ពីទទួលបានការអនុញ្ញាតចុះបញ្ជីលក់មូលបត្រក្នុងផ្សារមូលបត្រកម្ពុជា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវគោរពតាមលក្ខខណ្ឌដូចខាងក្រោម ៖

- អាចចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិក្នុងផ្សារមូលបត្រកម្ពុជា មិនលើសពី ២០% នៃសិទ្ធិបោះឆ្នោតនៅក្នុងគ្រឹះស្ថាន និង/ឬ
- អាចបោះផ្សាយសញ្ញាបណ្ណសាជីវកម្មលក់ក្នុងផ្សារមូលបត្រកម្ពុជា មិនលើសពី ២០% នៃទ្រព្យសកម្មសរុប។

### ២.១.៦. ក្របខ័ណ្ឌគ្រប់គ្រងសន្ទនីយភាពរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ក្នុងគោលដៅកាត់បន្ថយបញ្ហាសន្ទនីយភាពធ្ងន់ធ្ងរ កាត់បន្ថយផលប៉ះពាល់លើប្រព័ន្ធធនាគារ និងការពារអ្នកដាក់ប្រាក់បញ្ញើនិងឥណទាយក ធនាគារជាតិនៃកម្ពុជា កាលពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៧ បានចេញប្រកាសស្តីពីក្របខ័ណ្ឌគ្រប់គ្រងសន្ទនីយភាពរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលតម្រូវឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុរៀបចំក្របខ័ណ្ឌគ្រប់គ្រងហានិភ័យសន្ទនីយភាពឱ្យបានច្បាស់លាស់ ដើម្បីរក្សាសន្ទនីយភាពឱ្យបានគ្រប់គ្រាន់ជាប្រចាំ រួមទាំងការកាន់កាប់ទ្រព្យសកម្មមិនជាប់កាតព្វកិច្ច ដើម្បីទប់ទល់នឹងស្ថានភាពតានតឹងណាមួយ ពាក់ព័ន្ធនឹងការបាត់បង់ប្រភពទុន ដូចជា ប្រាក់បញ្ញើ ប្រាក់កម្ចី ការកៀរគរដើមទុនបន្ថែម និងបញ្ហាផ្សេងៗទៀត។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវធានាថាប្រភពទុនរបស់ខ្លួនមានស្ថិរភាពជាប្រចាំសម្រាប់គាំទ្រសកម្មភាពប្រតិបត្តិការ។ ទន្ទឹមនេះ គ្រឹះស្ថានត្រូវរាយការណ៍មកធនាគារជាតិនៃកម្ពុជាឱ្យបានឆាប់ នូវរាល់បញ្ហាសន្ទនីយភាពនាពេលបច្ចុប្បន្ន និងទៅអនាគត និងផែនការដោះស្រាយបញ្ហាទាំងនោះ។ ក្នុងករណីគ្រឹះស្ថានជួបប្រទះនឹងស្ថានភាពសន្ទនីយភាពតានតឹងធ្ងន់ធ្ងរ គ្រឹះស្ថានត្រូវជូនដំណឹងមកធនាគារជាតិនៃកម្ពុជាភ្លាមៗ ដោយបញ្ជាក់ពីវិធានការដោះស្រាយ។

### ២.១.៧. ការផ្តល់វិញ្ញាបនបត្រចំពោះគ្រឹះស្ថានឥណទានជនបទ

កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ធនាគារជាតិនៃកម្ពុជាបានចេញប្រកាសស្តីពីការផ្តល់វិញ្ញាបនបត្រចំពោះគ្រឹះស្ថានឥណទានជនបទ ដែលមានគោលដៅពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រង និងការត្រួតពិនិត្យគ្រឹះស្ថានដែលផ្តល់ឥណទានខ្នាតតូច។ បុគ្គលណាដែលមានបំណងដាក់ពាក្យស្នើសុំវិញ្ញាបនបត្រធ្វើប្រតិបត្តិការឥណទានជនបទ ត្រូវបំពេញឯកសារតាមលក្ខខណ្ឌដែលបានកំណត់ដោយធនាគារជាតិនៃកម្ពុជា និងមានដើមទុនចុះបញ្ជីអប្បបរមាចំនួន ២០០.០០០.០០០ រៀល (ពីររយ

លានរៀល) ព្រមទាំងត្រូវបង់ដើមទុនចុះបញ្ជីនេះ ១០០% នៅក្នុងគណនីដែលបានបើកនៅធនាគារជាតិនៃកម្ពុជា មុនពេលចាប់ផ្តើមប្រតិបត្តិការ។ គ្រឹះស្ថានត្រូវរក្សាប្រាក់តម្កល់ធានាលើដើមទុនស្មើនឹង ៥% នៃដើមទុនដែលបានចុះបញ្ជីនៅក្នុងគណនីដែលបានបើកនៅធនាគារជាតិនៃកម្ពុជា។

បន្ទាប់ពីទទួលបានពាក្យស្នើសុំពេញលេញ ធនាគារជាតិនៃកម្ពុជានឹងជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីសេចក្តីសម្រេចផ្តល់ ឬមិនផ្តល់វិញ្ញាបនបត្រក្នុងរយៈពេល ៣ខែ។ ក្នុងករណីធនាគារជាតិនៃកម្ពុជាសម្រេចផ្តល់វិញ្ញាបនបត្រ ធនាគារជាតិនៃកម្ពុជានឹងចេញលិខិតយល់ព្រមជាគោលការណ៍ ដោយមានលក្ខខណ្ឌដែលមានសុពលភាព ៦ខែ។ បន្ទាប់ពីគ្រឹះស្ថានបានបំពេញកាតព្វកិច្ចតាមលក្ខខណ្ឌនៃលិខិតយល់ព្រមជាគោលការណ៍ គ្រឹះស្ថានត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រពីធនាគារជាតិនៃកម្ពុជា។ ក្នុងករណីគ្រឹះស្ថានមិនបានបំពេញកាតព្វកិច្ចដែលមានចែងនៅក្នុងលិខិតយល់ព្រមជាគោលការណ៍ លិខិតនេះនឹងត្រូវចាត់ទុកជាមោឃៈ។

### ២.១.៨. សវនកម្មចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ដើម្បីធានានូវភាពត្រឹមត្រូវនិងសុចរិតភាពនៃព័ត៌មាន និងទិន្នន័យហិរញ្ញវត្ថុដែលសវនដ្ឋានផ្តល់ជូនធនាគារជាតិនៃកម្ពុជានិងភាគីពាក់ព័ន្ធ ព្រមទាំងលើកកម្ពស់ប្រសិទ្ធភាពនៃការត្រួតពិនិត្យដោយអនុលោមតាមស្តង់ដារនិងឧត្តមានុវត្តជាតិនិងអន្តរជាតិ ក៏ដូចជាពង្រឹងការងារសវនកម្មរបស់ក្រុមហ៊ុន ធនាគារជាតិនៃកម្ពុជាបានចេញប្រកាសស្តីពី សវនកម្មចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលតម្រូវឱ្យក្រុមហ៊ុនដែលមានបំណងធ្វើសវនកម្មលើគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវមានគុណវុឌ្ឍិដូចខាងក្រោម ៖

- បានចុះបញ្ជីពាណិជ្ជកម្ម
- ជាសមាជិកវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា (វ.គ.ស.ក.)
- មានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្ម ពីក្រុមប្រឹក្សាជាតិគណនេយ្យនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- មានដៃគូសវនកម្មនិងសវនករ ជាសមាជិកសកម្មនៅ វ.គ.ស.ក. យ៉ាងតិច ០២ រូប ដែលមានគុណវុឌ្ឍិគ្រប់គ្រាន់
- មានសកម្មភាពធុរកិច្ចសវនកម្ម និងមានកេរ្តិ៍ឈ្មោះល្អយ៉ាងតិច ០៣ ឆ្នាំ គិតមកដល់ថ្ងៃដាក់ពាក្យស្នើសុំ
- មានការពិនិត្យគុណភាពការងារសវនកម្មជាប្រចាំ និង
- បំពេញលក្ខខណ្ឌផ្សេងទៀតដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។

### ២.១.៩. ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមតែរមិន

កាលពីថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៧ ធនាគារជាតិនៃកម្ពុជាបានចេញប្រកាសស្តីពី ចំណាត់ថ្នាក់ហានិភ័យឥណទាននិងសំវិធានធនលើអ៊ីមតែរមិន ក្នុងគោលដៅកំណត់កាតព្វកិច្ចរបស់គ្រឹះស្ថាន

ធនាគារនិងហិរញ្ញវត្ថុ ក្នុងការអនុវត្តផ្នែកមួយនៃក្របខ័ណ្ឌគ្រប់គ្រងហានិភ័យឥណទានដោយប្រុងប្រយ័ត្ន និងបញ្ជាក់ពីភាពត្រឹមត្រូវនៃការទទួលស្គាល់ ការវាស់វែង ការធ្វើសំវិធានធន និងការរាយការណ៍ចំពោះហ្វាស៊ីលីធីដែលមានអ៊ីមភែរមិនរបស់គ្រឹះស្ថាន។ ការចាត់ថ្នាក់ហានិភ័យឥណទាននិងសំវិធានធនហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន គឺជាផ្នែកមួយនៃក្របខ័ណ្ឌគ្រប់គ្រងហានិភ័យទូទៅដែលគ្រឹះស្ថានត្រូវអនុវត្ត។ ដើម្បីគ្រប់គ្រងហានិភ័យឥណទានប្រកបដោយប្រសិទ្ធភាព គ្រឹះស្ថានត្រូវមាន ៖

- ប្រព័ន្ធគ្រប់គ្រងហានិភ័យឥណទានដែលមានលក្ខណៈសមស្របទៅនឹងចរិតលក្ខណៈ ភាពស្មុគស្មាញ និងទំហំនៃសកម្មភាពអាជីវកម្ម
- ការពិនិត្យឡើងវិញជាប្រចាំទៅលើប្រព័ន្ធគ្រប់គ្រងហានិភ័យឥណទាន ដោយផ្អែកលើការផ្លាស់ប្តូរស្ថានភាពសេដ្ឋកិច្ច សកម្មភាព អតិថិជន និងហានិភ័យនានា
- ប្រព័ន្ធគ្រប់គ្រងហានិភ័យប្រកបដោយប្រសិទ្ធភាពសម្រាប់ការកំណត់ជាមុន ការតាមដាន និងការវាស់វែងហានិភ័យឥណទានឱ្យបានត្រឹមត្រូវ រួមទាំងការកំណត់ឱ្យបានពេញលេញ និងការរាយការណ៍អំពីហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន និងការព្យាករណ៍ការខាតបង់នៃសំពៀតឥណទាន
- សំវិធានធនគ្រប់គ្រាន់សម្រាប់ហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន ស្របតាមស្តង់ដារគណនេយ្យជាធរមាននៃប្រទេសកម្ពុជា និង
- គោលនយោបាយ នីតិវិធី និងដំណើរការអនុវត្ត អនុលោមតាមលក្ខខណ្ឌតម្រូវទាំងអស់ដែលបានកំណត់។

## ២.២. សកម្មភាពនៃការត្រួតពិនិត្យ

ស្របពេលដែលប្រព័ន្ធធនាគារកម្ពុជាកំពុងពង្រីកវិសាលភាពនៃប្រតិបត្តិការរបស់ខ្លួន ធនាគារជាតិនៃកម្ពុជាបានបង្កើនសកម្មភាពត្រួតពិនិត្យប្រព័ន្ធធនាគារយ៉ាងខ្ជាប់ខ្ជួននិងប្រុងប្រយ័ត្ន តាមរយៈការត្រួតពិនិត្យដល់ទីកន្លែង ការត្រួតពិនិត្យលើឯកសារ និងការរៀបចំបទប្បញ្ញត្តិនានាឱ្យទាន់ពេលវេលាស្របតាមការរីកចម្រើននៃប្រព័ន្ធ។ ប្រព័ន្ធត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជាត្រូវបានអនុវត្តតាមការវាយតម្លៃប្រចាំគ្រា រួមមាន ត្រីមាស ឆមាស និងប្រចាំឆ្នាំ ដោយផ្អែកលើវិធីសាស្ត្រ CAMELS និងការត្រួតពិនិត្យផ្អែកលើហានិភ័យនិងទស្សនៈអនាគត ដើម្បីរក្សានូវស្ថិរភាពហិរញ្ញវត្ថុនិងភាពរឹងមាំនៃប្រព័ន្ធធនាគារទាំងមូលក្នុងការផ្តល់ទំនុកចិត្តដល់សាធារណជន។ សកម្មភាពនៃការត្រួតពិនិត្យត្រូវបានយកចិត្តទុកដាក់សំខាន់លើស្ថានភាពហិរញ្ញវត្ថុ អភិបាលកិច្ចល្អ ការអនុលោមតាមច្បាប់និងបទប្បញ្ញត្តិ និងហានិភ័យដែលអាចប៉ះពាល់ដល់អាជីវកម្មជាដើម។ ជាលទ្ធផលនៃការត្រួតពិនិត្យកន្លងមកបង្ហាញថា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានរក្សានូវស្ថានភាពល្អប្រសើរ ទាំងអភិបាលកិច្ចនិងស្ថានភាពហិរញ្ញវត្ថុ ប៉ុន្តែនៅមានចំណុចខ្វះខាតដែលទាមទារនូវការកែតម្រូវ ស្របតាមអនុសាសន៍ពីអាជ្ញាធរត្រួតពិនិត្យ។ ធនាគារជាតិនៃកម្ពុជានៅតែបន្តយកចិត្តទុកដាក់យ៉ាងមុតមាំក្នុងការត្រួតពិនិត្យ ដើម្បីធានាបាននូវប្រសិទ្ធភាព និងសុវត្ថិភាពនៃប្រព័ន្ធធនាគារកម្ពុជា។

## ៣. ការជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងសមាហរណកម្មក្នុងតំបន់

### ៣.១. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ

#### ៣.១.១. ស្តង់ដារគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ

ការអនុវត្តស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (CIFRS) ត្រូវបានដាក់ឱ្យអនុវត្តចាប់ពីឆ្នាំ២០១២ ដោយក្រុមប្រឹក្សាជាតិគណនេយ្យ។ ក៏ប៉ុន្តែដោយសារភាពស្មុគស្មាញនៃស្តង់ដារថ្មីនេះ ការអនុវត្តជាធរមានសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក៏ត្រូវបានអនុញ្ញាតឱ្យពន្យារពេលរហូតដល់ខែមករា ឆ្នាំ២០១៩។ ការពន្យារពេលនេះ គឺដើម្បីផ្តល់លទ្ធភាពឱ្យគ្រឹះស្ថានរៀបចំផែនការសកម្មភាពសម្រាប់ការអនុវត្តឱ្យបានច្បាស់លាស់ និងបណ្តុះបណ្តាលធនធានមនុស្សគ្រប់គ្រាន់ ក៏ដូចជាអនុញ្ញាតឱ្យធនាគារជាតិនៃកម្ពុជានិងគ្រប់ភាគីពាក់ព័ន្ធ កសាងធនធានគ្រប់គ្រាន់ក្នុងការគាំទ្រដល់ដំណើរការផ្លាស់ប្តូរទៅស្តង់ដារថ្មីនេះ ដោយរក្សាបាននូវភាពរឹងមាំនិងនិរន្តរភាពនៃប្រព័ន្ធធនាគារនៅកម្ពុជា។ ក្នុងគោលបំណងកាត់បន្ថយអសង្គតិភាពរវាងតម្រូវការរបាយការណ៍តាម CIFRS និងបទប្បញ្ញត្តិរបស់អាជ្ញាធរត្រួតពិនិត្យ និងដើម្បីពង្រឹងការងារសវនកម្មឯករាជ្យលើប្រព័ន្ធធនាគារ ក្នុងឆ្នាំ២០១៧ ធនាគារជាតិនៃកម្ពុជាបានពិនិត្យនិងកែសម្រួលបទប្បញ្ញត្តិទាក់ទងទៅនឹងការធ្វើចំណាត់ថ្នាក់ឥណទាន ការធ្វើសំវិធានធន និងការទទួលខុសត្រូវរបស់ក្រុមហ៊ុនសវនកម្មឯករាជ្យដែលធ្វើសវនកម្មមកលើគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផងដែរ។ ប្រកាសស្តីពីចំណាត់ថ្នាក់ហានិភ័យឥណទាននិងសំវិធានធនលើអ៊ីមភែរមិន ជាផ្នែកសំខាន់មួយនៃស្តង់ដារ CIFRS និងបានតម្រូវឱ្យគ្រឹះស្ថានអនុវត្តការធ្វើសំវិធានធនលើអ៊ីមភែរមិនស្របតាមស្តង់ដារគណនេយ្យ CIFRS ជាពិសេសគឺស្តង់ដារ IFRS 9 និងការកំណត់សំវិធានធនតាមបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា។ ប្រកាសនេះទាមទារឱ្យគ្រឹះស្ថានផ្លាស់ប្តូរវិធីសាស្ត្រក្នុងការធ្វើសំវិធានធន ផ្អែកលើមូលដ្ឋានហានិភ័យនិងទស្សនៈអនាគត សម្រាប់វាស់វែងជាមុននូវការខាតបង់ដែលអាចកើតមានឡើង (Expected Loss)។ រីឯប្រកាសស្តីពីសវនកម្មចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មានគោលបំណងពង្រឹងក្របខ័ណ្ឌនៃការទទួលស្គាល់សវនករ និងកំណត់ទំនាក់ទំនងកាន់តែមានប្រសិទ្ធភាពរវាងសវនករនិងអាជ្ញាធរត្រួតពិនិត្យ។ ធនាគារជាតិនៃកម្ពុជាកំពុងបន្តសិក្សាលម្អិតនិងរៀបចំផែនការសកម្មភាព សម្រាប់ឈានទៅការអនុវត្តស្តង់ដារ CIFRS ដោយសហការជាមួយអាជ្ញាធរពាក់ព័ន្ធ មានជាអាទិ៍ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហើយនឹងបន្តកសាងសមត្ថភាពទាក់ទងនឹងការប្រើប្រាស់ស្តង់ដារនេះឱ្យបានកាន់តែស៊ីជម្រៅ។

#### ៣.១.២. ការិយាល័យព័ត៌មានឥណទានកម្ពុជា

បន្ទាប់ពីដាក់ឱ្យដំណើរការកាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២ ទ្រព្យសកម្មសរុបរបស់ក្រុមហ៊ុនក្រេឌីតប្យួរ៉ូ (ខេមបូឌា) ខូ អិលធីឌី បានកើនឡើងដល់ ៤០ ប៊ីលានរៀល គិតត្រឹមដំណាច់ឆ្នាំ២០១៧ និងមានគ្រឹះស្ថានជាសមាជិកក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទានចំនួន ១៤៤ ដែលក្នុងនោះមាន

គ្រឹះស្ថានធនាគារពាណិជ្ជ ៣៩ គ្រឹះស្ថានធនាគារឯកទេស ១៤ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ៧ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ៦៧ ក្រុមហ៊ុនភតិសន្យា ១០ និងគ្រឹះស្ថានឥណទានជនបទ ៧។ សំពៀតឥណទានសរុបដែលគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានផ្តល់ និងបញ្ចូលទៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទានមានចំនួន ៦៥,៧ ទ្រីលានរៀល និងមានគណនីចំនួន ២.៧២១.៥៦១។

បច្ចុប្បន្ន ក្រុមហ៊ុនក្រេឌីតប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី បាននិងកំពុងប្រមូលទិន្នន័យឥណទានបុគ្គល ដោយពុំទាន់បានប្រមូលទិន្នន័យអំពីឥណទានក្រុមហ៊ុននៅឡើយទេ។ ដោយយល់ឃើញពីសារៈសំខាន់នៃទិន្នន័យឥណទានក្រុមហ៊ុន ក្រុមហ៊ុនក្រេឌីតប្យូរ៉ូបាននិងកំពុងអភិវឌ្ឍប្រព័ន្ធចែករំលែកព័ត៌មានឥណទានរបស់ខ្លួន ដើម្បីឱ្យគ្រឹះស្ថានជាសមាជិកអាចបញ្ចូលនិងទាញយករបាយការណ៍ព័ត៌មានឥណទានក្រុមហ៊ុនបានបន្ថែមលើទិន្នន័យឥណទានបុគ្គល។

ក្នុងការគាំទ្រដល់ការប្រមូលទិន្នន័យឥណទានក្រុមហ៊ុនរបស់ក្រុមហ៊ុនក្រេឌីតប្យូរ៉ូ កាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៧ ធនាគារជាតិនៃកម្ពុជាបានចេញសេចក្តីជូនដំណឹងដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ស្តីពីការផ្តល់ទិន្នន័យឥណទានក្រុមហ៊ុនចំនួន ៥០% នៃឥណទានសរុប សម្រាប់សាកល្បងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ដើម្បីឱ្យស្របតាមខ្លឹមសារប្រកាសស្តីពីការចែករំលែកព័ត៌មានឥណទាន។ ការប្រមូលទិន្នន័យឥណទានក្រុមហ៊ុននេះ នឹងបង្កើនលទ្ធភាពដល់គ្រឹះស្ថានជាសមាជិកក្នុងការស្វែងយល់បន្ថែមពីអតិថិជនរបស់ខ្លួនដែលជាក្រុមហ៊ុន ក៏ដូចជាបង្កើនលទ្ធភាពដល់ក្រុមហ៊ុនដែលមានប្រតិបត្តិការរឹងមាំ ឱ្យទទួលបានឥណទានប្រសើរជាងមុន ហើយការទទួលបាននូវទិន្នន័យនេះនឹងគាំទ្រដល់ធនាគារជាតិនៃកម្ពុជាផងដែរ ក្នុងការតាមដាននិងវិភាគលើស្ថានភាពឥណទានក្នុងវិស័យធនាគារកាន់តែពេញលេញ។

### ៣.១.៣. ប្រតិបត្តិការប្រព័ន្ធទូទាត់

ប្រព័ន្ធទូទាត់គឺជាហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុមួយដែលដើរតួនាទីយ៉ាងសំខាន់ ក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចនិងការធ្វើសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់និងសកល តាមរយៈការផ្តល់មធ្យោបាយផ្សេងៗសម្រាប់សម្រួលដល់ប្រតិបត្តិការទូទាត់ឱ្យមានភាពងាយស្រួលនិងរហ័ស។ ដោយមើលឃើញពីភាពសំខាន់នេះ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការជាផ្លូវការនូវប្រព័ន្ធសម្រាប់សេវាទូទាត់រហ័ស (Fast Payment) ដោយមានគ្រឹះស្ថានធនាគារពាណិជ្ជនិងមីក្រូហិរញ្ញវត្ថុទាំងអស់ជាសមាជិក។ ការដាក់ឱ្យដំណើរការសេវាទូទាត់រហ័សនឹងរួមចំណែកជំរុញការប្រើប្រាស់ប្រាក់រៀល និងការទូទាត់សងប្រាក់ជាអេឡិចត្រូនិកឱ្យកាន់តែមានប្រសិទ្ធភាព ព្រមទាំងលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុនិងការធ្វើទំនើបកម្មប្រព័ន្ធទូទាត់នៅកម្ពុជា។ ទន្ទឹមនេះ កាលពីថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការបឋមប្រព័ន្ធ Cambodian Shared Switch (CSS) ដោយមានគ្រឹះស្ថានសមាជិកចំនួន៥ ចូលរួម ហើយគ្រឹះស្ថានធនាគារពាណិជ្ជនិងមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើដទៃទៀតដែលជាសមាជិក បាននិងកំពុងបន្តធ្វើសមាហរណកម្មប្រព័ន្ធជាបន្តបន្ទាប់ (ដូចមានក្នុង

ឧបសម្ព័ន្ធ ៥)។ ក្នុងទិសដៅធ្វើទំនើបកម្មប្រព័ន្ធទូទាត់សងប្រាក់នៅកម្ពុជាឱ្យស្របតាមតម្រូវការទីផ្សារ និងឆ្លើយតបទៅនឹងការធ្វើសមាហរណកម្មប្រព័ន្ធទូទាត់ក្នុងតំបន់ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងអភិវឌ្ឍប្រព័ន្ធទូទាត់ដុលភ្លាមៗ សម្រាប់សម្រួលនិងកាត់បន្ថយហានិភ័យចំពោះប្រតិបត្តិការទូទាត់សងប្រាក់តម្លៃធំ។

ក្នុងក្របខ័ណ្ឌបទប្បញ្ញត្តិ កន្លងមកធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យប្រើប្រាស់ប្រកាសពាក់ព័ន្ធមួយចំនួនរួចមកហើយ ហើយដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលនិងការរីកចម្រើននៃសេវាទូទាត់សងប្រាក់ថ្មីៗនៅកម្ពុជាបច្ចុប្បន្ន ធនាគារជាតិនៃកម្ពុជាបាននិងកំពុងរៀបចំប្រកាសមួយចំនួនបន្ថែមទៀត រួមមាន ៖ i/- ប្រកាសស្តីពី *"ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ភ្នាក់ងារផ្តល់សេវាទូទាត់សងប្រាក់"* ii/- ប្រកាសស្តីពី *"ការគ្រប់គ្រងភ្នាក់ងាររបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ"* និង iii/-ប្រកាសស្តីពី *"ការការពារអតិថិជនចំពោះគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់"* ក្នុងគោលបំណងធានាភាពរឹងមាំ បង្កលក្ខណៈងាយស្រួលដល់ការត្រួតពិនិត្យ ការពារសុវត្ថិភាពមូលនិធិ និងធានាបានទំនុកចិត្តសាធារណជនទៅលើគ្រឹះស្ថានផ្តល់សេវាទូទាត់។ ទន្ទឹមនឹងការរៀបចំក្របខ័ណ្ឌបទប្បញ្ញត្តិ ធនាគារជាតិនៃកម្ពុជាក៏បាននិងកំពុងខិតខំពង្រឹងសមត្ថភាពមន្ត្រីពាក់ព័ន្ធក្នុងការអនុវត្តមុខងារត្រួតពិនិត្យ ដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងសុវត្ថិភាពរបស់ប្រព័ន្ធទូទាត់សងប្រាក់នៅកម្ពុជា។

## ៣.២. ការខារបរិយាប័ន្នហិរញ្ញវត្ថុ

អនុវត្តតាមស្មារតីនៃសេចក្តីថ្លែងការណ៍រួមរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា និងអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ សម្តេចតេជោនាយករដ្ឋមន្ត្រី ក្នុងឱកាសនៃសន្និសីទជាតិនៃវិស័យមីក្រូហិរញ្ញវត្ថុឆ្នាំ២០១៦ ធនាគារជាតិនៃកម្ពុជាបានផ្តល់វិញ្ញាបនបត្រចុះបញ្ជីជាប្រតិបត្តិករឥណទានជនបទ តាមរយៈការពិនិត្យនិងវាយតម្លៃយ៉ាងប្រុងប្រយ័ត្ន និងចុះត្រួតពិនិត្យដល់ទីកន្លែងដល់អង្គការមិនមែនរដ្ឋាភិបាល-សមាគម សរុបចំនួន ៣១៣ ក្នុងនោះ ១៤៣ ត្រូវបានផ្តល់វិញ្ញាបនបត្រក្នុងឆ្នាំ២០១៧។ គ្រឹះស្ថានឥណទានជនបទត្រូវបានតម្រូវឱ្យធ្វើការផ្លាស់ប្តូរទម្រង់គតិយុត្តិ ពីអង្គការមិនមែនរដ្ឋាភិបាល-សមាគមទៅជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតវិញ ដើម្បីកាត់បន្ថយការភ័ន្តច្រឡំរបស់សាធារណជនមកលើប្រតិបត្តិការរបស់ក្រុមហ៊ុនថា ជាប្រតិបត្តិការមិនស្វែងរកប្រាក់ចំណេញ។ ទន្ទឹមនេះ ដើម្បីពង្រឹងក្របខ័ណ្ឌគតិយុត្តិ និងលើកកម្ពស់ប្រសិទ្ធភាពនៃការត្រួតពិនិត្យទៅលើគ្រឹះស្ថាន ធនាគារជាតិនៃកម្ពុជាបានដាក់ចេញនូវប្រកាសស្តីពី ការផ្តល់វិញ្ញាបនបត្រចំពោះគ្រឹះស្ថានឥណទានជនបទ នៅដើមត្រីមាសទី៣ ឆ្នាំ២០១៧។

នៅក្នុងឆ្នាំ២០១៧ ធនាគារជាតិនៃកម្ពុជាបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីវិស័យមីក្រូហិរញ្ញវត្ថុ នៅតាមបណ្តាខេត្តចំនួន ២ គឺកំពង់ចាមនិងកណ្តាល ដោយមានការចូលរួមពីមន្ត្រីមកពីមន្ទីរជុំវិញខេត្ត ស្ថាប័នតុលាការខេត្ត អាជ្ញាធរមូលដ្ឋាននិងកងកម្លាំងមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ក្រុមយុវជនរបស់សហព័ន្ធយុវជនខេត្ត និស្សិត គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឃុំ-ស្រុក គ្រឹះស្ថានឥណទាន

ជនបទ ប្រធានភូមិ និងប្រជាពលរដ្ឋសរុបចំនួន ១.៣៨៥ នាក់។ សិក្ខាសាលានេះមានគោលបំណង បញ្ជ្រាបនិងលើកកម្ពស់ការយល់ដឹងដល់អាជ្ញាធរមូលដ្ឋាននិងប្រជាពលរដ្ឋ អំពីវិស័យមីក្រូហិរញ្ញវត្ថុ នៅកម្ពុជាតាមបណ្តាខេត្តនិងស្រុកនានានៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីឱ្យមានចំណេះដឹង ជាមូលដ្ឋាន និងជួយទប់ស្កាត់ការកេងបន្លំតាមគ្រប់រូបភាពពីជនអគតិឆ្លៀតឱកាសមួយចំនួន។

ការលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ គឺជាទិសដៅអាទិភាពមួយរបស់រាជរដ្ឋាភិបាលកម្ពុជា ដោយក្នុងនោះធនាគារជាតិនៃកម្ពុជារួមជាមួយនឹងក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ មានតួនាទីបង្កើត និងអនុវត្តយុទ្ធសាស្រ្តជាតិស្តីពីបរិយាប័ន្នហិរញ្ញវត្ថុ ស្របតាមយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១៦-២០២៥។ បន្ទាប់ពីការវិភាគភាពខ្វះចន្លោះត្រូវបានបញ្ចប់រួចរាល់ ផ្អែកលើលទ្ធផលនៃការ អង្កេតផ្នែកតម្រូវការនិងផ្នែកផ្គត់ផ្គង់ ក្រោមកិច្ចសហការជាមួយមូលនិធិអភិវឌ្ឍន៍មូលធនរបស់អង្គការ សហប្រជាជាតិ (United Nations Capital Development Fund) ក្រុមការងារអន្តរក្រសួង ដែលដឹកនាំ ដោយធនាគារជាតិនៃកម្ពុជា កំពុងរៀបចំសេចក្តីព្រាងនៃយុទ្ធសាស្រ្តជាតិសម្រាប់បរិយាប័ន្នហិរញ្ញវត្ថុ ដែលរំពឹងថានឹងត្រូវបានដាក់ឱ្យអនុវត្តនៅពាក់កណ្តាលឆ្នាំ២០១៨។

ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបានសហការជាមួយការិយាល័យមូលនិធិរូបិយវត្ថុអន្តរជាតិ ប្រចាំតំបន់អាស៊ី-ប៉ាស៊ីហ្វិក (OAP) រៀបចំសិក្ខាសាលាថ្នាក់តំបន់ ស្តីពីបរិយាប័ន្នហិរញ្ញវត្ថុ ដើម្បីចែក រំលែកបទពិសោធន៍និងវឌ្ឍនភាពនៃការងារបរិយាប័ន្នហិរញ្ញវត្ថុរបស់ប្រទេសក្នុងតំបន់ និងបង្ហាញពី លទ្ធផលនៃការស្រាវជ្រាវរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ អំពីទំនាក់ទំនងរវាងគោលនយោបាយម៉ាក្រូ សេដ្ឋកិច្ចនិងបរិយាប័ន្នហិរញ្ញវត្ថុ។ សិក្ខាសាលានេះមានការចូលរួមពីមន្ត្រីថ្នាក់ទេសាភិបាល និងមន្ត្រី ជាន់ខ្ពស់ពីស្ថាប័នធនាគារកណ្តាលនិងក្រសួងហិរញ្ញវត្ថុចំនួន ៣៩ ប្រទេសក្នុងតំបន់អាស៊ី ព្រមទាំង អង្គការអន្តរជាតិ ដូចជា មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងសហព័ន្ធ បរិយាប័ន្នហិរញ្ញវត្ថុ (AFI) ជាដើម។ ទោះបីអាស៊ីជាតំបន់ដែលមានកំណើនបរិយាប័ន្នហិរញ្ញវត្ថុខ្ពស់ ជាងគេ ប៉ុន្តែប្រទេសនៅក្នុងតំបន់នេះបានបង្ហាញគម្លាតខ្ពស់រវាងប្រទេសនិងប្រទេស កម្រិតប្រាក់ ចំណូល និងការអប់រំ។

### ៣.៣. ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងកិច្ចការពារអតិថិជន

ទន្ទឹមនឹងកិច្ចសហការជាមួយអង្គការ Good Return លើគម្រោងផ្លាស់ប្តូរឥរិយាបថរបស់អតិថិជន ចំពោះការប្រើប្រាស់សេវាហិរញ្ញវត្ថុ និងការងារកិច្ចការពារអតិថិជនជាមួយសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ធនាគារជាតិនៃកម្ពុជាបានផ្តោតការយកចិត្តទុកដាក់ចំពោះគម្រោងដាក់បញ្ជ្រាបចំណេះដឹងផ្នែក ហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាចំណេះដឹងទូទៅ ស្របតាមផែនការកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងគោលបំណងឱ្យសិស្សានុសិស្សទទួលបាននូវចំណេះដឹងផ្នែកហិរញ្ញវត្ថុ ជាមូលដ្ឋានសម្រាប់ ប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃរបស់ពួកគេ។ ក្រុមការងាររបស់ធនាគារជាតិនៃកម្ពុជាបានសហការ យ៉ាងជិតស្និទ្ធជាមួយក្រុមការងាររបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីពិភាក្សាលើកម្មវិធីសិក្សា

លម្អិតលើមុខវិជ្ជាដែលពាក់ព័ន្ធទាំង ៤ គឺ គេហ-សេដ្ឋកិច្ច បំណិនជីវិត សិក្សាសង្គម និងគណិតវិទ្យា។ ក្រុមការងារបានរៀបចំសិក្ខាសាលាចំនួន ៣ លើក ដើម្បីកំណត់នូវខ្លឹមសារមេរៀន និងលទ្ធផលសិក្សា ព្រមទាំងពិនិត្យមើលពីលទ្ធភាពក្នុងការបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុ ទៅក្នុងកម្មវិធីសិក្សាចំណេះទូទៅនៅកម្រិតបឋមសិក្សា កម្រិតមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ។ ចំពោះជំហានបន្ទាប់ ក្រុមការងារអប់រំផ្នែកហិរញ្ញវត្ថុរបស់ធនាគារជាតិនៃកម្ពុជា នឹងបន្តសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងភាគីពាក់ព័ន្ធ ដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី និងអង្គការ Good Return ជាដើម ដើម្បីបន្តអនុវត្តគម្រោងនេះដំណាក់កាលទី២ គឺការនិពន្ធ ការបោះពុម្ពសៀវភៅ ការបណ្តុះបណ្តាលគ្រូបង្គោល និងការអនុវត្តគម្រោងសាកល្បង (Pilot project) អំពីការបង្រៀនមុខវិជ្ជាផ្នែកហិរញ្ញវត្ថុ មុនពេលការអនុវត្តកម្មវិធីកំណែទម្រង់ថ្មីសម្រាប់ឆ្នាំសិក្សា២០១៨-២០១៩ ដែលនឹងត្រូវចាប់ផ្តើមក្នុងខែវិច្ឆិកា ឆ្នាំ២០១៨ ខាងមុខ។

ដើម្បីពង្រឹងយន្តការគាំពារអតិថិជន ធនាគារជាតិនៃកម្ពុជាបានបង្កើតក្រុមការងារគាំពារអតិថិជន និងបង្កើតប្រព័ន្ធ Hotline ដែលបានដាក់ឱ្យដំណើរការចាប់ពីខែសីហា ឆ្នាំ២០១៧ មក។ ធនាគារជាតិនៃកម្ពុជាបានចេញផ្សាយសេចក្តីជូនដំណឹងដល់សាធារណជន តាមប្រព័ន្ធបណ្តាញសង្គម Facebook ខិតប័ណ្ណ និងសារព័ត៌មានជាបន្តបន្ទាប់ អំពីការដាក់ឱ្យដំណើរការនូវប្រព័ន្ធទូរសព្ទចំនួន ៥ ខ្សែ នៅទីស្នាក់ការកណ្តាល និង ២១ ខ្សែទៀត នៅតាមបណ្តាសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត (ដូចមានក្នុងឧបសម្ព័ន្ធ ៦) ដើម្បីទទួលទូរសព្ទពីសាធារណជនដែលមានចម្ងល់ ឬបញ្ហា និងបណ្តឹងតវ៉ាផ្សេងៗ ពាក់ព័ន្ធនឹងការប្រើប្រាស់សេវាហិរញ្ញវត្ថុ។ នៅក្នុងឆ្នាំ២០១៧ ក្រុមការងារបានទទួលបណ្តឹងសរុបចំនួន ៤៤១ ករណី ដែលបណ្តឹងភាគច្រើនត្រូវបានដោះស្រាយនិងសម្របសម្រួលបានមួយភាគធំ រីឯបណ្តឹងមួយចំនួនទៀតត្រូវបានដោះស្រាយ ដោយមានការចូលរួមសហការពីបណ្តាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលពាក់ព័ន្ធ។ ទន្ទឹមនឹងនេះ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញប្រកាសស្តីពីការដោះស្រាយបណ្តឹងអតិថិជនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលតម្រូវឱ្យគ្រប់គ្រឹះស្ថានបង្កើតប្រព័ន្ធ Call Center ដើម្បីដោះស្រាយបណ្តឹងឬការតវ៉ាជូនអតិថិជនរបស់ខ្លួននៅដំណាក់កាលដំបូង។ ការបង្កើតប្រព័ន្ធ Hotline នេះ បានទទួលការគាំទ្រនិងអបអរសាទរពីសំណាក់ប្រជាពលរដ្ឋ ក្នុងបរិបទដែលការយល់ដឹងផ្នែកហិរញ្ញវត្ថុរបស់ប្រជាជននៅមានកម្រិត និងទាមទារឱ្យមានការផ្សព្វផ្សាយទូលំទូលាយទៅដល់មូលដ្ឋានថ្នាក់ខេត្ត-ស្រុកបន្ថែមទៀត។ ធនាគារជាតិនៃកម្ពុជានឹងបន្តអនុវត្តតាមមុខងារ-ភារកិច្ចរួមមាន ៖ ១/- ទទួលនិងដោះស្រាយបណ្តឹងបឋមជូនអតិថិជន ២/- បញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុដល់អតិថិជន ៣/- ផ្សព្វផ្សាយដំណឹងពីប្រព័ន្ធ Hotline ជូនសាធារណជន តាមរយៈសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត និងតាមរយៈបណ្តាញសង្គម Facebook និង ៤/- ណែនាំដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវពង្រឹងការណែនាំមន្ត្រីឥណទានរបស់ខ្លួន និងត្រូវចែងឱ្យបានច្បាស់លាស់នូវរាល់លក្ខខណ្ឌនានានៅក្នុងកិច្ចសន្យា ដើម្បីបញ្ជាក់ពីតម្លាភាពនៃការអនុវត្ត។

## ៣.៤. ការអភិវឌ្ឍទីផ្សារអន្តរធនាគារ

ប្រឈមនឹងបញ្ហាដុល្លារូបនីយកម្មខ្ពស់ ឧបករណ៍គោលនយោបាយរូបិយវត្ថុបន្តនៅមានកម្រិត ដែលទាមទារឱ្យមានការយកចិត្តទុកដាក់ជាពិសេសលើប្រសិទ្ធភាពនៃឧបករណ៍ដែលមានស្រាប់ និងការដាក់ឱ្យអនុវត្តនូវឧបករណ៍ថ្មីទៀត ដែលជាជំនួយដល់ការអនុវត្តគោលនយោបាយរូបិយវត្ថុ។ ចំពោះប្រសិទ្ធភាពនៃឧបករណ៍ដែលមានស្រាប់ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យប្រើប្រាស់ផ្ទៃតហ្វមធនាគារជាតិនៃកម្ពុជា (NBCP) ដែលជាប្រព័ន្ធអេឡិចត្រូនិកមួយផ្តល់ភាពងាយស្រួល តម្លាភាព និងឆាប់រហ័សដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងការទិញ/លក់រូបិយបណ្ណ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពទីផ្សារប្តូរប្រាក់ និងមូលបត្រអាចជួញដូរបាន (NCD) សំដៅជំរុញការអភិវឌ្ឍទីផ្សារទិញត្រឡប់វិញ (Repo) និងទីផ្សារអន្តរធនាគារ។ ផ្លែតហ្វមធនាគារជាតិនៃកម្ពុជារំពឹងថានឹងផ្តល់អត្ថប្រយោជន៍ដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដូចជា ១/- ផ្តល់ទីផ្សារមួយដែលមានសុវត្ថិភាពនិងតម្លាភាព ២/- បង្កើនជំនឿទុកចិត្តរវាងគ្រឹះស្ថាន ៣/- កាត់បន្ថយចំណាយប្រតិបត្តិការនិងចំណេញពេលវេលា និងសំខាន់បំផុត ៤/- ជំរុញការគ្រប់គ្រងសន្ទនីយភាពរបស់គ្រឹះស្ថានឱ្យកាន់តែមានប្រសិទ្ធភាព។

ធនាគារជាតិនៃកម្ពុជាបានបន្តជំរុញការអភិវឌ្ឍទីផ្សារកម្ចីអន្តរធនាគារ តាមរយៈឧបករណ៍សំខាន់ពីរគឺ ១/- មូលបត្រអាចជួញដូរបាន (NCD) និង ២/- ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO)។ មូលបត្រអាចជួញដូរបានត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១៣ ដើម្បីស្រូបយកសន្ទនីយភាពលើសនៅក្នុងប្រព័ន្ធធនាគារ ហើយបច្ចុប្បន្នគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុកាន់តែច្រើនបានប្រើប្រាស់វាជាទ្រព្យបញ្ចាំនៅក្នុងប្រតិបត្តិការ LPCO ក៏ដូចជាដើម្បីទទួលបានសន្ទនីយភាពរវាងគ្នានិងគ្នានៅក្នុងប្រតិបត្តិការទីផ្សារបន្ទាប់ (Secondary Market)។ ការដាក់ឱ្យមានប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានាកាលពីខែតុលា ឆ្នាំ២០១៦ ដែលជាការផ្តល់សន្ទនីយភាពជាប្រាក់រៀលក្នុងអត្រាប្រកួតប្រជែងដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បាននាំមកនូវផ្លែផ្កាក្នុងការចូលរួមចំណែកកាត់បន្ថយគម្លាតអត្រាការប្រាក់រវាងឥណទានជាប្រាក់រៀលនិងប្រាក់ដុល្លារអាមេរិក។ ជាក់ស្តែង LPCO គឺជាជម្រើសមួយសម្រាប់គ្រឹះស្ថានហិរញ្ញវត្ថុក្នុងការចរចា ដើម្បីទទួលបានកម្ចីពីក្រៅប្រទេសក្នុងអត្រាការប្រាក់ទាបជាងមុន ហើយក៏បានជំរុញឱ្យគ្រឹះស្ថានទាំងនេះងាកមកប្រើប្រាស់ប្រភពទុនក្នុងស្រុកដែលមានអត្រាការប្រាក់ទាបជាងប្រភពទុនក្រៅប្រទេស។ ទន្ទឹមនេះ គ្រឹះស្ថានកាន់តែច្រើនបានប្រើប្រាស់ LPCO ជាប្រភពទុនដើម្បីផ្តល់ឥណទានជារូបិយវត្ថុ ក្នុងខណៈដែលគ្រឹះស្ថានធនាគារបានប្រើប្រាស់ LPCO ដើម្បីផ្តល់ឥណទានជំបន្តដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុផងដែរ។ ក្នុងរយៈពេលវែង ប្រតិបត្តិការនេះនឹងបង្កើតឱ្យមានអត្រាការប្រាក់គោលមួយរបស់ធនាគារកណ្តាល ដែលធនាគារជាតិនៃកម្ពុជាអាចប្រើប្រាស់ដើម្បីតម្រង់ទិសអត្រាការប្រាក់ទីផ្សារ និងរួមចំណែកបន្ថែមមួយកម្រិតទៀតក្នុងការជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព។

## ៣.៥. ការផ្តល់ហិរញ្ញប្បទានវិស័យអចលនទ្រព្យ

វិស័យអចលនទ្រព្យនៅតែដើរតួនាទីយ៉ាងសំខាន់ក្នុងសេដ្ឋកិច្ចកម្ពុជា និងនៅបន្តទទួលបានហិរញ្ញប្បទានកាន់តែច្រើនឡើងពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ ការវិនិយោគនិងការផ្គត់ផ្គង់ផ្នែកអចលនវត្ថុនៅតែបន្តកើនឡើងក្នុងទីផ្សារអចលនវត្ថុកម្ពុជា ស្របគ្នានឹងការកើនឡើងជាលំដាប់នូវកម្រិតជីវភាពរស់នៅរបស់ប្រជាជន។ កម្រិតឥណទានរបស់គ្រឹះស្ថានធនាគារចំពោះវិស័យអចលនទ្រព្យដែលរួមមាន សកម្មភាពអចលនទ្រព្យ ការសាងសង់ និងការទិញផ្ទះសម្រាប់លំនៅដ្ឋាន បានបន្តកើនឡើងជាបន្តបន្ទាប់។ គិតត្រឹមដំណាច់ឆ្នាំ២០១៧ នេះ ឥណទានធនាគារនិងមីក្រូហិរញ្ញវត្ថុចំពោះវិស័យអចលទ្រព្យមានចំនួន ១៧.៣៦៣,៤១ ប៊ីលានរៀល ស្មើនឹង ២០,៣% នៃសំពៀតឥណទានសរុប។

តាមរយៈទិន្នន័យក្នុងប្រព័ន្ធរបាយការណ៍ប្រតិបត្តិការអន្តរជាតិ (ITRS) បានបង្ហាញថា លំហូរទុនវិនិយោគផ្ទាល់បរទេសក្នុងវិស័យអចលនទ្រព្យ (រួមបញ្ចូលនូវគ្រប់ប្រភេទអចលនទ្រព្យ និងខុនដូ) របស់កម្ពុជាក្នុងឆ្នាំ២០១៧ មានចំនួន ២.០៧១ ប៊ីលានរៀល រួមមាន ប្រទេសចិនចំនួន ៦១% ប្រទេសសិង្ហបុរី ១៦% និងប្រទេសផ្សេងៗទៀតមាន ២៣% នៃការវិនិយោគសរុប។

**តារាង ៥: លំហូរវិនិយោគក្នុងវិស័យអចលនទ្រព្យនៅកម្ពុជា** (គិតជាប៊ីលានរៀល)

| | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ |
|---|---|---|---|---|---|
| ការវិនិយោគជាដើមទុននៅកម្ពុជា | ៣.៨២៣ | ៦.៦៧៥ | ៤.២០០ | ៤.២៧៩ | ១១.៦១០ |
| ការវិនិយោគក្នុងវិស័យអចលនទ្រព្យ | ៤០៧ | ១.៧៨១ | ១.៥៣៩ | ១.២៩៦ | ២.០៧១ |

ប្រភព ៖ ការប៉ាន់ស្មានក្នុងប្រព័ន្ធ ITRS របស់ធនាគារជាតិនៃកម្ពុជា

**រូបភាព១០: លំហូរចូលនៃការវិនិយោគផ្ទាល់បរទេសក្នុងវិស័យអចលនទ្រព្យនៅកម្ពុជា**




ប្រភព ៖ ប្រព័ន្ធ ITRS របស់ធនាគារជាតិនៃកម្ពុជា

វិស័យអចលនទ្រព្យមានហានិភ័យខ្ពស់ ដែលទាមទារឱ្យមានការតាមដាននិងត្រួតពិនិត្យជាប្រចាំ ដើម្បីចៀសវាងនូវហានិភ័យផ្សេងៗដែលអាចកើតមាន។ អាស្រ័យដោយហេតុថា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុកាន់តែច្រើនឡើងបន្តផ្តល់ឥណទានដល់វិស័យនេះ ធនាគារជាតិនៃកម្ពុជាបានយកចិត្តទុកដាក់ជាពិសេសលើការវិវឌ្ឍនៃទីផ្សារអចលនវត្ថុនៅកម្ពុជា តាមរយៈការត្រួតពិនិត្យយ៉ាងជិតដល់លើដំណើរការ និងប្រតិបត្តិការរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទាំងអស់ ក៏ដូចជាបន្តប្រមូលព័ត៌មានពាក់ព័ន្ធសម្រាប់ការវិភាគពីភាពងាយរងគ្រោះ និងហានិភ័យដែលអាចកើតមាន។

**រូបភាព១១: ចំណែកទីផ្សារឥណទានទៅវិស័យអចលនទ្រព្យរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ**




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

វិស័យធនាគារនៅតែបន្តចូលរួមចំណែកយ៉ាងសកម្មដល់ការអភិវឌ្ឍវិស័យអចលនទ្រព្យនៅកម្ពុជា។ ៩៦% នៃឥណទានដល់វិស័យអចលនទ្រព្យផ្តល់ដោយគ្រឹះស្ថានធនាគារ និង ៤% ផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ គិតត្រឹមដំណាច់ឆ្នាំ២០១៧ ផលធៀបឆ្នាំលើឆ្នាំនៃកំណើនឥណទានធនាគារ និងមីក្រូហិរញ្ញវត្ថុចំពោះវិស័យអចលនទ្រព្យមានកម្រិត ៣៧,៣៤% និង ៦៧,៧៨% រៀងគ្នា។ ថ្វីត្បិតតែចំណែកទីផ្សារឥណទានចំពោះវិស័យអចលនទ្រព្យរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានទំហំតូចខ្លាំងបើធៀបទៅនឹងធនាគារក៏ដោយ ប៉ុន្តែកំណើនឥណទានដ៏ខ្ពស់ចំពោះវិស័យនេះទាមទារឱ្យមានការត្រួតពិនិត្យជាប្រចាំលើប្រតិបត្តិការរបស់គ្រឹះស្ថានដែលពាក់ព័ន្ធ។

**រូបភាព ១២: ឥណទានទៅវិស័យអចលនទ្រព្យ**




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

សំណង់និងការទិញផ្ទះសម្រាប់លំនៅដ្ឋានបានបន្តកើនឡើង និងទទួលបានការគាំទ្រផ្នែកហិរញ្ញប្បទានកាន់តែច្រើនពីវិស័យធនាគារ អាស្រ័យដោយហេតុថា អត្រាប្រជាជនមានការងារធ្វើ និងមានប្រាក់ចំណូលមធ្យមបន្តកើនឡើងជាបន្តបន្ទាប់ ដែលជាកត្តាជំរុញឱ្យមានការកើនឡើងនូវតម្រូវការឥណទានសម្រាប់ទិញផ្ទះជាលំនៅដ្ឋាន។ មួយវិញទៀត ការប្រែប្រួលក្នុងទម្លាប់នៃការរស់នៅក៏ជាកត្តាជំរុញឱ្យមានការកើនឡើងនូវឥណទានទៅលើវិស័យអចលនទ្រព្យផងដែរ ដែលក្នុងពេលបច្ចុប្បន្នប្រជាជនស្ថិតក្នុងវ័យកណ្តាលដែលមានការងារធ្វើ និងមានប្រាក់ចំណូលមធ្យម ចង់រស់នៅក្នុងផ្ទះដែលជាកម្មសិទ្ធិផ្ទាល់ខ្លួន ជាជាងរស់នៅជាមួយឪពុកម្តាយក្រោយពេលរៀបការ។ ការវិនិយោគលើខុនដូនិងលំនៅដ្ឋានប្រណីតមានការថយចុះ ដោយវិនិយោគិនផ្តោតលើការវិនិយោគលំនៅដ្ឋានសម្រាប់គ្រួសារមានចំណូលទាបនិងមធ្យម។ គិតត្រឹមដំណាច់ឆ្នាំ២០១៧ នេះ ៧៦% នៃឥណទានទៅវិស័យអចលនទ្រព្យ ត្រូវបានផ្តល់ទៅសកម្មភាពសាងសង់និងការទិញផ្ទះសម្រាប់លំនៅដ្ឋាន និង ២៤% ត្រូវបានផ្តល់ទៅសកម្មភាពជួញដូរអចលនវត្ថុ។

## ៣.៦. យន្តការការពារអ្នកដាក់ប្រាក់បញ្ញើ

ផ្អែកលើស្ថានភាពវិស័យធនាគារកម្ពុជាបច្ចុប្បន្ន កម្ពុជាពិតជាត្រូវការប្រព័ន្ធការពារប្រាក់បញ្ញើដោយសារ ៖ ១/- គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមួយចំនួនជាគ្រឹះស្ថានដែលងាយរងផលប៉ះពាល់ដោយការធ្លាក់ចុះនៃសេដ្ឋកិច្ច ទោះបីជាស្ថានភាពម៉ាក្រូសេដ្ឋកិច្ចនិងប្រព័ន្ធហិរញ្ញវត្ថុនៅមានភាពរឹងមាំក៏ដោយ ២/- ស្ថិរភាពប្រព័ន្ធធនាគារនិងការការពារប្រាក់បញ្ញើមានសារៈសំខាន់ក្នុងការបង្កើនទំនុកចិត្តរបស់អ្នកដាក់ប្រាក់បញ្ញើ ៣/- វិស័យហិរញ្ញវត្ថុនៅកម្ពុជាងាយនឹងរងឥទ្ធិពលខាងក្រៅដោយសារបញ្ហាដុល្លាវូបនីយកម្ម ៤/- យន្តការច្បាស់លាស់ក្នុងការបិទ ឬដោះស្រាយលើគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលមានបញ្ហាអាចបញ្ចៀសឥទ្ធិពលអាក្រក់ និងការពារកុំឱ្យបញ្ហារាលដាលជាប្រព័ន្ធ និង ៥/- ប្រព័ន្ធការពារប្រាក់បញ្ញើគឺជាធាតុមួយសំខាន់នៃយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ក្នុងការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុប្រកបដោយភាពរឹងមាំ ប្រសិទ្ធភាព និងពិពិធកម្ម។ បុរេលក្ខខណ្ឌក្នុងការបង្កើតប្រព័ន្ធការពារប្រាក់បញ្ញើគឺ ១/- បរិបទបទប្បញ្ញត្តិប្រុងប្រយ័ត្ន ២/- សំណាញ់សុវត្ថិភាពហិរញ្ញវត្ថុ ៣/- ការផ្តល់ព័ត៌មានដោយគ្រឹះស្ថានពាក់ព័ន្ធ ៤/- សិទ្ធិអំណាចតាមផ្លូវច្បាប់ក្នុងការបង្កើត ៥/- ការការពារស្របច្បាប់ និង ៦/- មូលនិធិក្នុងការបង្កើតនិងធ្វើប្រតិបត្តិការ។

ក្នុងប្រទេសជាច្រើននៅអាស៊ី ដែលរួមមាន ជប៉ុន កូរ៉េ ម៉ាឡេស៊ី ឥណ្ឌូណេស៊ី វៀតណាម ថៃ និង សិង្ហបុរី ប្រព័ន្ធការពារប្រាក់បញ្ញើត្រូវបានបង្កើតឡើងជាស្ថាប័នឯករាជ្យដោយច្បាប់ ក្នុងទម្រង់ជាគ្រឹះស្ថានសាធារណៈឬឯកជន ហើយដោយមានវិស័យធនាគារជាវិស័យចម្បងក្នុងទីផ្សារហិរញ្ញវត្ថុ ប្រទេសទាំងនេះផ្តល់ការការពារលើគ្រឹះស្ថានធនាគារ រីឯគ្រឹះស្ថានហិរញ្ញវត្ថុមិនមែនធនាគារផ្សេងទៀតអាចចូលជាសមាជិកនៃប្រព័ន្ធការពារប្រាក់បញ្ញើ យោងលើទំហំនិងកម្រិតហានិភ័យនៃអនុវិស័យនីមួយៗ។ ប្រទេសភាគច្រើនអនុវត្តតាមគំរូ Pay Box ឬ Pay Box Plus (លើកលែងតែប្រទេសជប៉ុន កូរ៉េ ម៉ាឡេស៊ី និងឥណ្ឌូណេស៊ី) ក្នុងនោះស្ថាប័នការពារប្រាក់បញ្ញើមានមុខងារចម្បងប្រមូលនិងគ្រប់គ្រង

បុព្វលាភ និងធ្វើការត្រួតពិនិត្យដល់ទីកន្លែងដើម្បីផ្ទៀងផ្ទាត់អំពីភាពត្រឹមត្រូវនៃការគណនាបុព្វលាភ។ ប្រទេសទាំងនេះកំណត់យកអត្រាបុព្វលាភថេរពីគ្រឹះស្ថានជាសមាជិក យ៉ាងហោចសម្រាប់ដំណាក់កាលដំបូង មុននឹងឈានទៅកំណត់តាមកម្រិតហានិភ័យរបស់គ្រឹះស្ថាន។ ជាជំហានដំបូងសម្រាប់កម្ពុជា ប្រព័ន្ធការពារប្រាក់បញ្ញើគួរតែត្រូវបានបង្កើតឡើងតាមម៉ូដែលសាមញ្ញ មានប្រសិទ្ធភាព និងងាយស្រួលអនុវត្ត ដែលអាចបំពេញគោលដៅសំខាន់ពីរគឺ ១/- ផ្តល់ការការពារដល់ប្រាក់បញ្ញើមិនឱ្យបាត់បង់ត្រឹមចំនួនធានាអតិបរមា និង ២/- លើកកម្ពស់និងចូលរួមរក្សាស្ថិរភាពហិរញ្ញវត្ថុ។

ធនាគារជាតិនៃកម្ពុជាបានទទួលជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍន៍នានា ដូចជា រតនាគារសហរដ្ឋអាមេរិក (US Department of the Treasury) វិទ្យាស្ថានធនាគារអភិវឌ្ឍន៍អាស៊ី (ADB Institute) ធនាគារពិភពលោក (World Bank) សាជីវកម្មធានារ៉ាប់រងប្រាក់បញ្ញើរបស់សាធារណរដ្ឋកូរ៉េ (KDIC) និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA)។ ជំនួយបច្ចេកទេសទាំងនេះមានគោលបំណង ៖ ១/- វាយតម្លៃអំពីលទ្ធភាពបង្កើតប្រព័ន្ធការពារប្រាក់បញ្ញើក្នុងលក្ខខណ្ឌនៃប្រព័ន្ធហិរញ្ញវត្ថុកម្ពុជា និង ២/- បណ្តុះបណ្តាលសមត្ថភាពមន្ត្រីពាក់ព័ន្ធលើគោលការណ៍សំខាន់ៗនៃប្រព័ន្ធនេះ ក្របខ័ណ្ឌច្បាប់ និងស្ថាប័ន ប្រភេទគ្រឹះស្ថាននិងប្រាក់បញ្ញើដែលមានការការពារ ការកំណត់បុព្វលាភ មូលនិធិ និងប្រភពទុន ជាដើម។ យោងលើក្របខ័ណ្ឌបទប្បញ្ញត្តិដែលមានស្រាប់ គួបផ្សំជាមួយនឹងបទពិសោធន៍ទទួលបានពីប្រទេសក្នុងតំបន់ គំរូ Pay Box Plus គឺជាគំរូដែលមានលក្ខណៈសមស្របបំផុត នៅក្នុងបរិបទនៃប្រព័ន្ធហិរញ្ញវត្ថុកម្ពុជាបច្ចុប្បន្ន ហើយក៏មានភាពសាមញ្ញនិងងាយស្រួលអនុវត្តក្នុងដំណាក់កាលបង្កើតដំបូងផងដែរ។ ដូចនេះ ក្នុងជំហានបន្ទាប់ ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១៦-២០២៥ ធនាគារជាតិនៃកម្ពុជាកំពុងសិក្សាលើក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិដែលពាក់ព័ន្ធក្នុងការបង្កើតប្រព័ន្ធការពារប្រាក់បញ្ញើផ្អែកលើគំរូ Pay Box Plus។

## ៤. ការកសាងសមត្ថភាពត្រួតពិនិត្យ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ

### ៤.១. ការកសាងសមត្ថភាពមន្ត្រីត្រួតពិនិត្យ

នៅក្នុងឆ្នាំ២០១៧ ធនាគារជាតិនៃកម្ពុជាបានបញ្ជូនមន្ត្រីត្រួតពិនិត្យទៅចូលរួមកិច្ចប្រជុំនិងវគ្គបណ្តុះបណ្តាលរយៈពេលខ្លីនៅក្នុងប្រទេសនានាក្នុងទ្វីបអាស៊ី រួមមាន ជប៉ុន ហ្វីលីពីន ហុងកុង ថៃ ឡាវ វៀតណាម ឥណ្ឌូណេស៊ី ឥណ្ឌា សិង្ហបុរី ម៉ាឡេស៊ី និងកូរ៉េ ក្នុងទ្វីបអឺរ៉ុប រួមមាន ស្វីស និងទួកគី នៅទ្វីបអាហ្វ្រិក គឺប្រទេសអេហ្ស៊ីប ព្រមទាំងសហរដ្ឋអាមេរិកនិងប្រទេសអូស្ត្រាលី និងទទួលការបណ្តុះបណ្តាល FSI-Connect ដែលរៀបចំដោយធនាគារសម្រាប់ការទូទាត់អន្តរជាតិ (BIS) ផងដែរ។ ក្នុងគោលដៅពង្រឹងសមត្ថភាពរយៈពេលវែង មន្ត្រីវ័យក្មេងបានទទួលការសិក្សាអប់រំទាំងក្នុងប្រទេសតួយ៉ាងជំនាញគណនេយ្យ ACCA (Association of Chartered Certified Accountants) នៅវិទ្យាស្ថាន CamEd និងក្រៅប្រទេស ដូចជា កូរ៉េ ចិន សហរដ្ឋអាមេរិក និងអូស្ត្រាលី ជាដើម ដែលឆ្លើយតបទៅនឹងវឌ្ឍនភាពនៃវិស័យធនាគារនិងហិរញ្ញវត្ថុនាពេលខាងមុខ។

## ៤.២. កិច្ចសហប្រតិបត្តិការអន្តរជាតិ

ធនាគារជាតិនៃកម្ពុជានិងអាជ្ញាធរត្រួតពិនិត្យជាដៃគូទាំងក្នុងតំបន់និងអន្តរជាតិ បាននិងកំពុងបន្តលើកកម្ពស់កិច្ចសហប្រតិបត្តិការ ក្នុងគោលបំណងធានាបាននូវប្រសិទ្ធភាពនៃការអនុវត្តការងារជាពិសេស ការចែករំលែកនូវបទពិសោធន៍នៃការត្រួតពិនិត្យ។ កាលពីថ្ងៃទី៧-៨ ខែធ្នូ ឆ្នាំ២០១៧ ធនាគារជាតិនៃកម្ពុជាបានសហការជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ រៀបចំសិក្ខាសាលាស្តីពី បរិយាប័ន្នហិរញ្ញវត្ថុនៅក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក ៖ ទិសដៅអនាគត នៅខេត្តសៀមរាប គោលបំណងចែករំលែកចំណេះដឹង អំពីស្ថានភាពនៃបរិយាប័ន្នហិរញ្ញវត្ថុនៅក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក ឥទ្ធិពលនៃបរិយាប័ន្នហិរញ្ញវត្ថុក្នុងការអភិវឌ្ឍសេដ្ឋកិច្ច កាត់បន្ថយភាពក្រីក្រនិងវិសមភាពចំណូល ទំនាក់ទំនងរវាងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងបរិយាប័ន្នហិរញ្ញវត្ថុ ឥទ្ធិពលនៃបច្ចេកវិទ្យាហិរញ្ញវត្ថុ និងទិសដៅនៃការជំរុញបរិយាប័ន្នហិរញ្ញវត្ថុនាពេលអនាគត ដោយមានសិក្ខាកាមចូលរួមចំនួន ៦៥នាក់ ដែលមកពីបណ្តាធនាគារកណ្តាល អាជ្ញាធរត្រួតពិនិត្យ ក្រសួងហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍នានា មកពី ១៧ប្រទេសក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។

ក្នុងឆ្នាំ២០១៧ ធនាគារជាតិនៃកម្ពុជាបានចុះអនុស្សរណៈយោគយល់ជាមួយអាជ្ញាធរត្រួតពិនិត្យជាដៃគូមួយចំនួន រួមមាន ៖ ១/- អនុស្សរណៈយោគយល់ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យធនាគារ រវាងធនាគារជាតិនៃកម្ពុជានិងធនាគារកណ្តាលថៃ ក្នុងឱកាសកិច្ចប្រជុំក្រុមប្រឹក្សាទេសាភិបាល SEACEN លើកទី៣៧ ២/- កិច្ចព្រមព្រៀងទ្វេភាគីស្តីពីការស្រាវជ្រាវរួមគ្នារវាងធនាគារជាតិនៃកម្ពុជានិងធនាគារកណ្តាលកូរ៉េ ក្នុងសិក្ខាសាលា "ភាពជាដៃគូផ្តល់ចំណេះដឹង" ក្រោមប្រធានបទ "ទំនាក់ទំនងរវាងអត្រាប្តូរប្រាក់និងអតិផរណានៅក្នុងសេដ្ឋកិច្ចកម្ពុជា" ៣/- អនុស្សរណៈយោគយល់ស្តីពីការផ្លាស់ប្តូរព័ត៌មានទាក់ទងនឹងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម រវាងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជានិងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុមីយ៉ាន់ម៉ា ៤/- កិច្ចប្រជុំទ្វេភាគីរវាងធនាគារជាតិនៃកម្ពុជានិងធនាគារកណ្តាលថៃ ក្នុងគោលបំណងពង្រឹងចំណងសាមគ្គីភាព ភាតរភាពមេត្រីភាព និងកិច្ចសហប្រតិបត្តិការ និង ៥/- កិច្ចប្រជុំទ្វេភាគីរវាងធនាគារជាតិនៃកម្ពុជានិងធនាគាររដ្ឋវៀតណាម ក្នុងគោលបំណងពង្រឹងចំណងសាមគ្គីភាព ភាតរភាព មេត្រីភាព និងកិច្ចសហប្រតិបត្តិការ។ ឆ្លងតាមកិច្ចសហប្រតិបត្តិការខាងលើ ធនាគារជាតិនៃកម្ពុជានៅតែបន្តពង្រឹងកិច្ចសហប្រតិបត្តិការសំដៅកសាងសមត្ថភាពធនធានមនុស្ស ក៏ដូចជាលើកកម្ពស់ភាពរឹងមាំនៃប្រព័ន្ធធនាគារនៅកម្ពុជាតាមរយៈការពង្រីកបណ្តាញទំនាក់ទំនងជាមួយគ្រឹះស្ថាន អាជ្ញាធរត្រួតពិនិត្យទាំងក្នុងនិងក្រៅតំបន់ ក៏ដូចជាការបញ្ជូនមន្ត្រីជំនាញទៅចូលរួមវគ្គបណ្តុះបណ្តាល និងកម្មវិធីផ្លាស់ប្តូរបទពិសោធន៍ការងារនានា។

# បញ្ជីឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ១

**ទិន្នន័យរបស់គ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជាឆ្នាំ២០១៧**
**ជាភាសាអង់គ្លេស**

## ឧបសម្ព័ន្ធ២

**អត្រាការប្រាក់លើប្រាក់បញ្ញើនិងឥណទាន ជាប្រាក់រៀលនិងរូបិយបណ្ណ**

## ឧបសម្ព័ន្ធ៣

**ប្រព័ន្ធធនាគារកម្ពុជា**

## ឧបសម្ព័ន្ធ៤

**បញ្ជីឈ្មោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ**
**ជាភាសាអង់គ្លេស**

## ឧបសម្ព័ន្ធ៥

ប្រព័ន្ធ FAST Payment និង Cambodian Shared Switch ( CSS )

## ឧបសម្ព័ន្ធ៦

**បញ្ជីលេខទូរសព្ទទំនាក់ទំនងអំពីចម្ងល់និងបញ្ហាពាក់ព័ន្ធនឹង**
**ការប្រើប្រាស់សេវាហិរញ្ញវត្ថុ**

## ឧបសម្ព័ន្ធ ២ ក

## អត្រាការប្រាក់លើការឲ្យខ្ចីចងការ (ប្រាក់រៀល និងរូបិយប័ណ្ណ)

### ប្រចាំខែធ្នូ ឆ្នាំ២០១៧

(អត្រាប្រចាំឆ្នាំ)

| ល.រ | ឈ្មោះធនាគារ | ឥណទានជារៀល | | | | ឥណទានជាដុល្លារ | | | | ឥណទានជារូបិយប័ណ្ណផ្សេងៗ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ១ខែ | ៣ខែ | ៦ខែ | ១២ខែ | ១ខែ | ៣ខែ | ៦ខែ | ១២ខែ | ១ខែ | ៣ខែ | ៦ខែ | ១២ខែ |
| **ធនាគារពាណិជ្ជ** | | | | | | | | | | | | | |
| 1 | ធនាគារ អេស៊ីលីដា | | | | 13.8% | | | | 10.0% | | | | 14.4% |
| 2 | ធនាគារ វឌ្ឍនៈអាស៊ី | | | | 9.2% | | 9.5% | 9.5% | 8.3% | | | | |
| 3 | ធនាគារ កសិកម្មនិងអភិវឌ្ឍន៍ជនបទ វៀតណាម សាខាកម្ពុជា (អាហ្គ្រីប៊ែង) | 16.8% | 16.8% | 16.8% | 16.8% | 10.0% | 10.0% | 10.0% | 10.0% | | | | |
| 4 | ធនាគារ អេអ៊ិនហ្សេតរ៉ូយ៉ាល់ | | | | | | | | 5.6% | | | | |
| 5 | ធនាគារ បាងកក មហាជន ទទួលខុសត្រូវមានកម្រិត សាខាកម្ពុជា | | | | | 9.0% | 9.0% | 9.0% | 9.0% | | | | |
| 6 | ធនាគារ វិនិយោគនិងអភិវឌ្ឍន៍កម្ពុជា | | | | | 10.0% | 10.0% | 10.0% | 10.0% | | | | |
| 7 | ធនាគារ ចិន សាខាភ្នំពេញ | | | | | | | | 11.0% | | | | |
| 8 | ធនាគារ ឥណ្ឌា | | | | | | | | 12.0% | | | | |
| 9 | ធនាគារ ប៉ូយ៉ុងខ្មែរ | | | | | | | | 9.0% | | | | |
| 10 | សាខាធនាគារ កសិកន ផាប់ប្លិក ខមភេនី លីមីធីត (ភ្នំពេញ) | | | | | | 6.3% | 6.0% | | | | | |
| 11 | សាខាធនាគារ មីហ្ស៊ូហូ អិលធីឌី | | | | | | | | | | | | |
| 12 | ធនាគារ ប្រេដ ប៊ែង (ខេមបូឌា) ភីអិលស៊ី | 10.5% | 10.5% | 11.0% | 17.0% | 8.5% | 8.5% | 15.0% | 15.0% | | | | |
| 13 | ធនាគារ កម្ពុជាអាស៊ី | | | | | | | | 12.0% | | | | |
| 14 | ធនាគារ មេគង្គកម្ពុជា | | | | | | | | 12.0% | | | | |
| 15 | ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ | | | 18.0% | 31.2% | | | 18.0% | 30.0% | | | | 30.0% |
| 16 | ធនាគារ កម្ពុជាពាណិជ្ជ | | | | | 10.5% | 10.5% | 10.5% | 10.5% | 10.5% | 10.5% | 10.5% | 10.5% |
| 17 | ធនាគារ កម្ពុជាសាធារណៈ | | | | | 9.0% | 9.0% | 9.0% | 9.0% | | | | |
| 18 | ធនាគារ កាណាឌីយ៉ា | | | | 11.0% | | | | 11.5% | | | | 12.8% |
| 19 | ធនាគារ កាថេ យូណៃធីត កម្ពុជា ចំកាត់ | | | | | | | | 8.7% | | | | |
| 20 | ធនាគារ ស៊ី អាយ អ៊ឹមប៊ី | | | | | 12.0% | 12.0% | 12.0% | 12.0% | | | | |
| 21 | ធនាគារ ពាណិជ្ជ ទី១ | | | | | 11.0% | 11.0% | 11.0% | 11.0% | | | | |
| 22 | ធនាគារ ពាណិជ្ជកម្មក្រៅប្រទេស | 18.0% | 18.0% | 18.0% | 18.0% | 18.0% | 18.0% | 18.0% | 18.0% | | | | |
| 23 | ធនាគារ  ហុង លីអុង (ខេមបូឌា) ភីអិលស៊ី | | | | | | | | 8.0% | | | | |
| 24 | ធនាគារ អាយ ស៊ី ប៊ី ស៊ី | | | | | | | 2.8% | 8.5% | | | 3.6% | 1.4% |
| 25 | ធនាគារ គូកមីន កម្ពុជា | | | | | 15.0% | 15.0% | 15.0% | 15.0% | | | | |
| 26 | ធនាគារ ក្រុងថៃ | | | | | | | | 6.0% | | | | |
| 27 | ធនាគារ មេយប៊ែង (ខេមបូឌា) ភីអិលស៊ី | | | | | | | | 12.3% | | | | |
| 28 | ធនាគារ អ៊ឹម ប៊ី | | | | | 10.3% | 10.3% | 10.3% | 10.3% | | | | |
| 29 | ធនាគារ មេហ្គា អ៊ិនធើណេសិនណល ខមមើសល សាខាភ្នំពេញ | | | | | | | | 8.0% | | | | |
| 30 | ធនាគារ ហ្វីលីព ភីអិលស៊ី | | | | | | | | 12.0% | | | | |
| 31 | ធនាគារ ភ្នំពេញពាណិជ្ជ | | | 14.0% | 15.3% | | | 14.0% | 15.3% | | | | |
| 32 | ធនាគារ អ អេច ប៊ី ឥណ្ឌូឆាយណា | | | | | | | | 14.0% | | | | |
| 33 | ធនាគារ សាយហ្គន ធឿនទីន ខេមបូឌា ភីអិលស៊ី | 14.4% | 14.4% | 14.4% | 14.4% | 14.4% | 14.4% | 14.4% | 14.4% | | | | |
| 34 | ធនាគារ ស្ថាបនា ភីអិលស៊ី | 18.0% | 18.0% | 18.0% | 18.0% | 18.0% | 18.0% | 18.0% | 18.0% | 18.0% | 18.0% | 18.0% | 18.0% |
| 35 | ធនាគារ សៃហ្គន-ហាណូយកម្ពុជា លីមីធីត (អេស ហេជ ប៊ី) | | | | | | | | 8.0% | | | | |
| 36 | ធនាគារ ស៊ិនហានខ្មែរ | | | | | 15.0% | 15.0% | 15.0% | 15.0% | | | | |
| 37 | ធនាគារ តៃវ៉ាន់ ខូអបភើរេធីវ សាខាភ្នំពេញ | | | | | | | | 11.1% | | | | |
| 38 | ធនាគារ សហពាណិជ្ជ ក.អ | | | | | 7.5% | 12.0% | 11.0% | 14.4% | | | | |
| 39 | ធនាគារ វឌ្ឍនៈ | | | | | 12.0% | 12.0% | 12.0% | 12.0% | | | | |

# ឧបសម្ព័ន្ធ ២ ក

## អត្រាការប្រាក់លើការឲ្យខ្ចីចងការ (ប្រាក់រៀល និងរូបិយប័ណ្ណ)

### ប្រចាំខែធ្នូ ឆ្នាំ២០១៧

(អត្រាប្រចាំឆ្នាំ)

| ល.រ | ឈ្មោះធនាគារ | ឥណទានជារៀល | | | | ឥណទានជាដុល្លារ | | | | ឥណទានជារូបិយប័ណ្ណផ្សេងៗ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ១ខែ | ៣ខែ | ៦ខែ | ១២ខែ | ១ខែ | ៣ខែ | ៦ខែ | ១២ខែ | ១ខែ | ៣ខែ | ៦ខែ | ១២ខែ |
| **ធនាគារឯកទេស** | | | | | | | | | | | | | |
| 40 | ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី | | | | | | | 40.9% | 43.8% | | | | |
| 41 | ធនាគារឯកទេស អានកូ | | | | | | | | 21.5% | | | | |
| 42 | ធនាគារឯកទេស អង្គរ កាពីតាល | | | | | | | | 16.0% | | | | |
| 43 | ធនាគារឯកទស អេស៊ា-ប៉ាស៊ីហ្វិក ឌីវេឡុបមេន | | | | | | | | 8.3% | | | | |
| 44 | ធនាគារឯកទេស ខេមខូ | | | | | | | | 18.0% | | | | |
| 45 | ធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី | | 18.0% | 18.0% | 18.0% | | 18.0% | 18.0% | 18.0% | | | | |
| 46 | ធនាគារឯកទេស ឌី ជី ប៊ី | | | | | | | | 24.0% | | | | |
| 47 | ធនាគារឯកទេស វិនិយោគទី១ | | | | | | | | 18.0% | | | | |
| 48 | ធនាគារឯកទស ខ្មែរ ភីអិលស៊ី | | | | | | | | 11.0% | | | | |
| 49 | ធនាគារឯកទេស អកស៍ឡី វើលដ៏ប្រ៊ិដ ភីអិលស៊ី | | | | 6.0% | | | | 8.0% | | | | |
| 50 | ធនាគារឯកទេស ភី អេច អែស អ៊ឹម អ៊ី | | | | | | | | 18.0% | | | | |
| 51 | ធនាគារឯកទេស អភិវឌ្ឍន៍ជនបទ | | | | 14.0% | | | | 9.0% | | | | |
| 52 | ធនាគារឯកទេស សាវធើន ខាប់ភីផល ភីអិលស៊ី | | | | | | 10.0% | 10.0% | 8.0% | | | | |
| 53 | ធនាគារឯកទេស តូមាតូ | | | | | | | | 12.0% | | | | |
| 54 | ធនាគារឯកទេស វីង (ខេមបូឌា) លីមីតធីត | | | 6.0% | | | | | | | | | |
| **មធ្យមភាគអត្រាការប្រាក់ក្រោយការថ្លឹង** | | **18.0%** | **18.0%** | **18.0%** | **14.5%** | **12.5%** | **12.2%** | **11.9%** | **11.7%** | **17.3%** | **17.3%** | **11.6%** | **13.8%** |
| **មធ្យមភាគអត្រាការប្រាក់** | | **15.5%** | **16.0%** | **14.9%** | **15.6%** | **11.9%** | **11.9%** | **13.3%** | **13.1%** | **14.3%** | **14.3%** | **10.7%** | **14.5%** |

## ឧបសម្ព័ន្ធ ២ ខ

### អត្រាការប្រាក់លើប្រាក់បញ្ញើ (ប្រាក់រៀល និងរូបិយប័ណ្ណ)

### ប្រចាំខែធ្នូ ឆ្នាំ២០១៧

(អត្រាប្រចាំឆ្នាំ)

| ល.រ | ឈ្មោះធនាគារ | ប្រាក់បញ្ញើជារៀល | | | | | ប្រាក់បញ្ញើជាដុល្លារ | | | | | ប្រាក់បញ្ញើជារូបិយប័ណ្ណផ្សេងៗ | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សំចៃ | ប្រាក់បញ្ញើមានកាលកំណត់ | | | | សំចៃ | ប្រាក់បញ្ញើមានកាលកំណត់ | | | | សំចៃ | ប្រាក់បញ្ញើមានកាលកំណត់ | | | |
| | | | ១ខែ | ៣ខែ | ៦ខែ | ១២ខែ | | ១ខែ | ៣ខែ | ៦ខែ | ១២ខែ | | ១ខែ | ៣ខែ | ៦ខែ | ១២ខែ |
| **ធនាគារពាណិជ្ជ** | | | | | | | | | | | | | | | | |
| 1 | ធនាគារ អេស៊ីលីដា | 1.3% | 2.0% | 3.5% | 4.3% | 5.8% | 0.5% | 0.8% | 2.0% | 3.0% | 4.8% | 0.1% | 0.1% | 0.5% | 1.0% | 2.0% |
| 2 | ធនាគារ វឌ្ឍនៈអាស៊ី | 1.0% | 2.3% | 4.0% | 4.8% | 6.3% | 0.5% | 1.5% | 2.8% | 3.8% | 5.0% | | | | | |
| 3 | ធនាគារ កសិកម្មនិងអភិវឌ្ឍន៍ជនបទ វៀតណាម សាខាកម្ពុជា (អាហ្គ្រីប៊ែង) | 0.5% | 2.0% | 3.0% | 3.8% | 4.5% | 0.5% | 1.5% | 2.5% | 3.3% | 3.8% | | | | | |
| 4 | ធនាគារ អេអ៊ិនហ្សេតរ៉ូយ៉ាល់ | | 3.3% | 3.5% | 4.0% | 5.5% | 0.5% | 0.3% | 0.5% | 1.5% | 2.0% | | | | | |
| 5 | ធនាគារ បាងកក មហាជន ទទួលខុសត្រូវមានកម្រិត សាខាកម្ពុជា | 0.3% | 0.8% | 1.0% | 1.5% | 2.0% | 0.5% | 1.0% | 1.5% | 2.5% | 3.5% | 0.1% | | 0.3% | | 0.8% |
| 6 | ធនាគារ វិនិយោគនិងអភិវឌ្ឍន៍កម្ពុជា | | 3.5% | 4.6% | 5.6% | 6.5% | 0.5% | 2.0% | 3.0% | 4.0% | 5.3% | | | | | |
| 7 | ធនាគារ ចិន សាខាភ្នំពេញ | 0.1% | 0.1% | 0.1% | 0.1% | 0.1% | 0.5% | 1.5% | 1.8% | 3.0% | 3.5% | 0.4% | 1.5% | 1.8% | 3.0% | 3.5% |
| 8 | ធនាគារ ឥណ្ឌា | | | | | | 0.8% | 1.0% | 1.5% | 2.0% | 2.8% | | | | | |
| 9 | ធនាគារ ប៉ូយ៉ុងខ្មែរ | 1.0% | 3.0% | 4.0% | 5.0% | 6.0% | 0.5% | 1.5% | 2.5% | 3.0% | 3.5% | | | | | |
| 10 | សាខាធនាគារ កសិកន ផាប់ប្លិក ខមភេនី លីមីធីត (ភ្នំពេញ) | | | | | | 0.1% | | 1.0% | 1.4% | | | | | | |
| 11 | សាខាធនាគារ មីហ្សូហូ អិលធីឌី | | | | | | | | | | | | | | | |
| 12 | ធនាគារ ប្រេដ ប៊ែង (ខេមបូឌា) ភីអិលស៊ី | 2.0% | | 4.0% | 5.0% | 6.0% | 1.0% | | 2.3% | 3.0% | 4.0% | 1.0% | | 2.3% | 3.0% | 4.0% |
| 13 | ធនាគារ កម្ពុជាអាស៊ី | | | | | | 2.0% | 2.5% | 3.8% | 4.8% | 5.8% | | | | | |
| 14 | ធនាគារ មេគង្គកម្ពុជា | 3.8% | | | | | 2.0% | | 2.8% | 3.5% | 4.0% | | | | | |
| 15 | ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ | 1.5% | 3.5% | 3.5% | 4.5% | 6.5% | 1.3% | 3.0% | 3.0% | 4.0% | 6.0% | 1.5% | 3.5% | 3.5% | 4.5% | 6.5% |
| 16 | ធនាគារ កម្ពុជាពាណិជ្ជ | 0.4% | | 1.5% | 1.5% | 1.5% | 1.0% | 1.5% | 2.0% | 2.3% | 2.5% | 0.4% | | 1.5% | 1.5% | 1.5% |
| 17 | ធនាគារ កម្ពុជាសាធារណៈ | 0.4% | 1.5% | 3.0% | 3.8% | 4.5% | 0.4% | 1.0% | 1.8% | 3.0% | 3.8% | 0.4% | | | | |
| 18 | ធនាគារ កាណាឌីយ៉ា | 2.0% | | 5.0% | 6.0% | 7.0% | 0.8% | 2.0% | 2.5% | 3.5% | 4.8% | 0.3% | 1.0% | 1.5% | 2.0% | 2.5% |
| 19 | ធនាគារ កាថេ យូណៃធីត កម្ពុជា ចំកាត់ | | | 5.0% | 6.0% | 7.0% | 0.5% | | 2.0% | 2.5% | 4.0% | | | | | |
| 20 | ធនាគារ ស៊ី អាយ អ៊ឹមប៊ី | | | | | | 1.5% | 1.5% | 2.3% | 3.3% | 4.0% | | 2.5% | 3.5% | 4.3% | 5.0% |
| 21 | ធនាគារ ពាណិជ្ជ ទី១ | | | | | | 0.4% | 1.3% | 1.5% | 2.0% | 3.0% | | | | | |
| 22 | ធនាគារ ពាណិជ្ជកម្មក្រៅប្រទេស | 1.5% | 3.0% | 5.0% | 6.0% | 7.0% | 0.8% | 1.5% | 2.5% | 3.8% | 5.0% | | | | | |
| 23 | ធនាគារ ហុង លីអុង (ខេមបូឌា) ភីអិលស៊ី | 0.8% | | | | | 0.5% | 1.8% | 2.5% | 3.8% | 4.8% | | | | | |
| 24 | ធនាគារ អាយ ស៊ី ប៊ី ស៊ី | | | 1.5% | | | 0.5% | 1.5% | 2.3% | 3.0% | 3.5% | | | 2.9% | 3.0% | 3.1% |
| 25 | ធនាគារ គូកមីន កម្ពុជា | 0.7% | 1.7% | 2.5% | 3.2% | 3.6% | 0.5% | 1.2% | 2.0% | 2.7% | 3.1% | | | | | |
| 26 | ធនាគារ ក្រុងថៃ | | | | | | 0.1% | | 0.5% | 0.8% | 1.0% | | | | | |
| 27 | ធនាគារ មេយប៊ែង (ខេមបូឌា) ភីអិលស៊ី | | | | | | 1.5% | 2.5% | 3.0% | 4.0% | 5.0% | | | | | |
| 28 | ធនាគារ អ៊ឹម ប៊ី | 0.8% | 3.5% | 4.5% | 5.0% | 6.0% | 0.5% | 2.8% | 3.2% | 4.2% | 5.0% | | | | | |
| 29 | ធនាគារ មេហ្គា អ៊ិនធើណេសិនណល ខមមើសល សាខាភ្នំពេញ | | | | | | 0.0% | 0.4% | 0.6% | 0.8% | 1.1% | | | | | |
| 30 | ធនាគារ ហ្វីលីព ភីអិលស៊ី | | | | | | 1.0% | 2.3% | 2.8% | 3.5% | 5.0% | | | | | |
| 31 | ធនាគារ ភ្នំពេញពាណិជ្ជ | 1.3% | | 3.3% | 4.3% | 5.5% | 2.0% | 1.0% | 3.0% | 4.0% | 5.3% | | | | | |
| 32 | ធនាគារ អ អេច ប៊ី ឥណ្ឌូឆាយណា | 1.0% | 3.5% | 4.0% | 5.0% | 6.0% | 1.0% | 2.0% | 2.5% | 3.5% | 4.8% | | | | | |
| 33 | ធនាគារ សាយហ្គន ធឿនទីន ខេមបូឌា ភីអិលស៊ី | 0.5% | 3.0% | 4.5% | 5.0% | 6.3% | 0.5% | 2.4% | 3.3% | 3.8% | 5.1% | | | | | |
| 34 | ធនាគារ ស្ថាបនា ភីអិលស៊ី | 2.0% | 4.0% | 5.0% | 5.5% | 7.5% | 1.5% | 3.5% | 4.0% | 4.5% | 6.5% | 1.5% | 3.5% | 4.0% | 4.5% | 6.5% |
| 35 | ធនាគារ សៃហ្គន-ហាណូយកម្ពុជា លីមីធីត (អេស ហេជ ប៊ី) | | 2.9% | 3.8% | 5.5% | 5.5% | | 3.8% | 4.8% | 4.9% | 5.8% | | | | | |
| 36 | ធនាគារ ស៊ិនហានខ្មែរ | | | | | | 0.1% | 1.3% | 2.3% | 3.5% | 4.2% | | | | | |
| 37 | ធនាគារ តៃវ៉ាន់ ខូអបភើរេធីវ សាខាភ្នំពេញ | | | | | | 0.3% | 0.8% | 1.0% | 1.3% | 1.6% | | | | | |
| 38 | ធនាគារ សហពាណិជ្ជ ក.អ | 1.3% | | 3.0% | 3.8% | 4.5% | 1.0% | | 2.0% | 2.5% | 3.0% | | | | | |
| 39 | ធនាគារ វឌ្ឍនៈ | 0.5% | 1.5% | 2.0% | 3.0% | 3.5% | 0.5% | 1.5% | 2.0% | 3.0% | 3.5% | | | | | |

## ឧបសម្ព័ន្ធ ២ ខ

## អត្រាការប្រាក់លើប្រាក់បញ្ញើ ( ប្រាក់រៀល និងរូបិយប័ណ្ណ )

### ប្រចាំខែធ្នូ ឆ្នាំ២០១៧

(អត្រាប្រចាំឆ្នាំ)

| ល.រ | ឈ្មោះធនាគារ | ប្រាក់បញ្ញើជារៀល | | | | | ប្រាក់បញ្ញើជាដុល្លារ | | | | | ប្រាក់បញ្ញើជារូបិយប័ណ្ណផ្សេងៗ | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សំចៃ | ប្រាក់បញ្ញើមានកាលកំណត់ | | | | សំចៃ | ប្រាក់បញ្ញើមានកាលកំណត់ | | | | សំចៃ | ប្រាក់បញ្ញើមានកាលកំណត់ | | | |
| | | | ១ខែ | ៣ខែ | ៦ខែ | ១២ខែ | | ១ខែ | ៣ខែ | ៦ខែ | ១២ខែ | | ១ខែ | ៣ខែ | ៦ខែ | ១២ខែ |
| ធនាគារឯកទេស | | | | | | | | | | | | | | | | |
| 40 | ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី | | | | | | | | | | | | | | | |
| 41 | ធនាគារឯកទេស អានកូ | | | | | | | | | | | | | | | |
| 42 | ធនាគារឯកទេស អង្គរ កាពីតាល | | | | | | | | | | | | | | | |
| 43 | ធនាគារឯកទស អេស៊ា-ប៉ាស៊ីហ្វិក ឌីវេឡុបមេន | | | | | | | | | | | | | | | |
| 44 | ធនាគារឯកទេស ខេមខូ | | | | | | | | | | | | | | | |
| 45 | ធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី | | | | | | | | | | | | | | | |
| 46 | ធនាគារឯកទេស ឌី ជី ប៊ី | | | | | | | | | | | | | | | |
| 47 | ធនាគារឯកទេស វិនិយោគទី១ | | | | | | | | | | | | | | | |
| 48 | ធនាគារឯកទស ខ្មែរ ភីអិលស៊ី | | | | | | 0.8% | | | | | | | | | |
| 49 | ធនាគារឯកទេស អកស៍ឡី វើលដ៏ប្រ៊ិជ ភីអិលស៊ី | | | | | | | | | | | | | | | |
| 50 | ធនាគារឯកទេស ភី អេច អែស អ៊ឹម អ៊ី | | | | | | | | | | | | | | | |
| 51 | ធនាគារឯកទេស អភិវឌ្ឍន៍ជនបទ | 1.5% | 3.5% | 4.0% | 5.0% | 6.0% | 1.0% | 3.0% | 3.5% | 4.0% | 5.0% | | | | | |
| 52 | ធនាគារឯកទេស សាវធើន ខាប់ភីផល ភីអិលស៊ី | | | | | | | | | | | | | | | |
| 53 | ធនាគារឯកទេស តូមាតូ | | | | | | | | | | | | | | | |
| 54 | ធនាគារឯកទេស វីង (ខេមបូឌា) លីមីតធីត | | | | | | | | | | | | | | | |
| **មធ្យមភាគអត្រាការប្រាក់ក្រោយការថ្លឹង** | | **1.4%** | **2.2%** | **3.9%** | **4.7%** | **5.9%** | **0.7%** | **1.5%** | **2.3%** | **3.3%** | **4.4%** | **0.3%** | **1.1%** | **1.6%** | **2.2%** | **3.0%** |
| **មធ្យមភាគអត្រាការប្រាក់** | | **1.1%** | **2.5%** | **3.4%** | **4.3%** | **5.2%** | **0.8%** | **1.7%** | **2.3%** | **3.1%** | **4.0%** | **0.6%** | **2.0%** | **2.2%** | **3.0%** | **3.5%** |

## ឧបសម្ព័ន្ធ ៣

# ប្រព័ន្ធធនាគារនៅកម្ពុជា

ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧

**ធនាគារជាតិនៃកម្ពុជា**
**(ធនាគារកណ្តាល)**

### ៣៩ ធនាគារពាណិជ្ជ

#### ១១ សាខាធនាគារបរទេស

១. ធនាគារ ពាណិជ្ជ ទី១
២. ធនាគារ ក្រុងថៃ
៣. ធនាគារ ឥណ្ឌា
៤. ធនាគារ ចិន សាខាភ្នំពេញ
៥. ធនាគារ មេហ្គា អ៊ិនធើណេសិនណល ខមមើសល សាខាភ្នំពេញ
៦. ធនាគារ អាយ ស៊ី ប៊ី ស៊ី
៧. ធនាគារ អ៊ឹម ប៊ី
៨. ធនាគារ តៃវ៉ាន់ ខូអបភើរេធីវ សាខាភ្នំពេញ
៩. ធនាគារ បាងកក មហាជន ទទួលខុសត្រូវមានកម្រិត សាខាកម្ពុជា
១០. សាខាធនាគារ កសិកន ផាប់ប្លីក ខមភេនីលីមីធីត (ភ្នំពេញ)
១១. សាខាធនាគារ មីហ្សូហូ អិលធីឌី

#### ១២ បង្កើតឡើងក្នុងស្រុក

១. ធនាគារ ពាណិជ្ជកម្មក្រៅប្រទេស
២. ធនាគារ វឌ្ឍនៈអាស៊ី
៣. ធនាគារ កម្ពុជាអាស៊ី
៤. ធនាគារ កាណាឌីយ៉ា
៥. ធនាគារ មេគង្គកម្ពុជា
៦. ធនាគារ វឌ្ឍនៈ
៧. ធនាគារ អេស៊ីលីដា
៨. ធនាគារ វិនិយោគនិងអភិវឌ្ឍន៍កម្ពុជា
៩. ធនាគារ ស្ថាបនា ភីអិលស៊ី
១០. ធនាគារ ប៉ូយ៉ុងខ្មែរ
១១. ធនាគារ ភ្នំពេញពាណិជ្ជ
១២. ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ

#### ១៦ បុត្តសម្ព័ន្ធធនាគារ

១. ធនាគារ កម្ពុជាពាណិជ្ជ
២. ធនាគារ កម្ពុជាសាធារណៈ
៣. ធនាគារ មេយប៊ែង (ខេមបូឌា) ភីអិលស៊ី
៤. ធនាគារ អេអ៊ិនហ្សេតរ៉ូយ៉ាល់
៥. ធនាគារ ស៊ិនហានខ្មែរ
៦. ធនាគារ គូកមីន កម្ពុជា
៧. ធនាគារ អ អេច ប៊ី ឥណ្ឌូឆាយណា
៨. ធនាគារ ស៊ី អាយ អ៊ឹមប៊ី
៩. ធនាគារ សាយហ្គន ធឿនទីន ខេមបូឌា ភីអិលស៊ី
១០. ធនាគារ ហុង លីអុង (ខេមបូឌា) ភីអិលស៊ី
១១. ធនាគារ កាថេ យូណៃធីត កម្ពុជា ចំកាត់
១២. ធនាគារ សហពាណិជ្ជ ក.អ
១៣. ធនាគារ ហ្វីលីព ភីអិលស៊ី
១៤. ធនាគារ សៃហ្គន-ហាណូយកម្ពុជា លីមីធីត (អេស ហេជ ប៊ី)
១៥. ធនាគារ ប្រេដ ប៊ែង (ខេមបូឌា) ភីអិលស៊ី
១៦. ធនាគារ កសិកម្មនិងអភិវឌ្ឍន៍ជនបទ វៀតណាម សាខាកម្ពុជា (អាហ្គ្រីប៊ែង)

### ១៥ ធនាគារឯកទេស

#### ១ ធនាគាររដ្ឋ

១. ធនាគារឯកទេស អភិវឌ្ឍន៍ជនបទ

#### ៥ បង្កើតឡើងក្នុងស្រុក

១. ធនាគារឯកទេស វិនិយោគទី១
២. ធនាគារឯកទេស អានកូ
៣. ធនាគារឯកទេស វីង (ខេមបូឌា) លីមីតធីត
៤. ធនាគារឯកទស ខ្មែរ ភីអិលស៊ី
៥. ធនាគារឯកទស អេស៊ា-ប៉ាស៊ីហ្វិក ឌីវេឡុបមេន

#### ៩ ធនាគារបរទេស

១. ធនាគារឯកទេស ភី អេច អែស អ៊ឹម អ៊ី
២. ធនាគារឯកទេស តូមាតូ
៣. ធនាគារឯកទេស អង្គរ កាពីតាល
៤. ធនាគារឯកទេស ខេមខូ
៥. ធនាគារឯកទេស ឌី ជី ប៊ី
៦. ធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី
៧. ធនាគារឯកទេស អកស៍ឡី វើលដ៏ប្រ៊ិដ ភីអិលស៊ី
៨. ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី
៩. ធនាគារឯកទេស សាវធើន ខាប់ភីផល ភីអិលស៊ី

### ៦ ការិយាល័យតំណាង

១. ធនាគារ ស្តង់ដារឆាទីរ៉េត
២. ធនាគារ វិនិយោគនិងអភិវឌ្ឍន៍នៃវៀតណាម
៣. ធនាគារ ប៊ែង អហ្វ តូក្យូ មីតស៊ុយប៊ីស៊ី
៤. ធនាគារ ស៊ូមីតូម៉ូមីតស៊ុយ ប៊ែងឃីង ខបភើរេសិន
៥. ធនាគារ សៀង ហៃ ខមមែសល & សវីង
៦. ធនាគារ អ៊ិនដាស ស្រៀល ប៊ែង អហ្វ ខូរៀ

### ២.៤៧៨ អាជីវកម្មប្តូរប្រាក់

| | | |
|---|---|---|
| **ភ្នំពេញ** | : | **១១៨** |
| -អាជ្ញាប័ណ្ណ | : | ៧៥ |
| -លិខិតអនុញ្ញាត | : | ៤៣ |
| **ខេត្ត** | : | **២.៣៦០** |
| -អាជ្ញាប័ណ្ណ | : | ០២ |
| -លិខិតអនុញ្ញាត | : | ២.៣៥៨ |

## ៧៦ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

### ៦៩ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

១. សីលានិធិ
២. អាតូម ខែភីថល
៣. ម៉ាក់ស៊ីម៉ា
៤. ឥណទានពលរដ្ឋរុងរឿង
៥. សាមិក
៦. ឥណទានអភិវឌ្ឍន៍ប្រជាជន
៧. ហ្វាម័រ ហ្វាយនែន
៨. វែលខម ហ្វាយនែន
៩. ហ្វីស ហ្វាយនែន
១០. វ៉ាយ ស៊ី ភី ម៉ាយក្រូហ្វាយនែន
១១. សំរិទ្ធិស័ក មីក្រូហិរញ្ញវត្ថុ
១២. ខេមា មីក្រូហិរញ្ញវត្ថុ
១៣. ខេមរៈ
១៤. ប្រាយ៍ម អិម អេហ្វ
១៥. សូណាត្រា
១៦. អ៊ូរី ហ្វាយនែន ខេមបូឌា ភីអិលស៊ី
១៧. ចំរើន ម៉ាយក្រូហ្វាយនែន
១៨. អាក់ទីវ ភីភល
១៩. បាយ័ន ក្រេឌីត
២០. បរិបូណ៌
២១. យី ភីអិលស៊ី
២២. ស៊ីធី ភីអិលស៊ី
២៣. លី ហ្វូរ ភីអិលស៊ី
២៤. អមតៈខាប់ភីថល
២៥. សច្ចៈ ម៉ាយក្រូហ្វាយនែន
២៦. អ្នូរ៉ូ ហ្វាយនែនខប ភីអិលស៊ី
២៧. នីរន្តរ មីក្រូហិរញ្ញវត្ថុភីអិលស៊ី
២៨. ឌ្រែលតា ម៉ាយក្រូហ្វាយនែន ភីអិលស៊ី
២៩. សេនជូរី ខេមបូឌីវេឡុបមេន ភីអិលស៊ី
៣០. តាកា ម៉ាយក្រូហ្វាយនែន ភីអិលស៊ី
៣១. ពិភពថ្មី មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី
៣២. សិរីឧត្តម មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី
៣៣. សម្បត្តិ ហ្វាយនែន ភីអិលស៊ី
៣៤. ប៊ី អេន ខេ ស៊ី (ខេមបូឌា) ភីអិលស៊ី
៣៥. ប៉ែមប៊ូ ហ្វាយនែន ភីអិលស៊ី
៣៦. សហគ្រិនភាព ម៉ាយក្រូហ្វាយនែន ភីអិលស៊ី
៣៧. សែលកាត ហ្វាយនែន ភីអិលស៊ី
៣៨. ធីប៊ីប៊ី (ខេមបូឌា) ភីអិលស៊ី
៣៩. មហានគរ មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី
៤០. រ៉ូយ៉ាល់ម៉ាយក្រូហ្វាយនែន ភីអិលស៊ី
៤១. អេផល ហ្វាយនែន ភីអិលស៊ី
៤២. ហ្វូណនមីក្រូហ្វាយនែន
៤៣. ព្រីនស៍ មីក្រូហ្វាយនែន
៤៤. សម្ព័ន្ធសហគមន៍ សហគ្រាសធុនតូច និងមធ្យម
៤៥. សាមគ្គី មីក្រូហ្វាយនែន អ៊ិនស៊ុធ្យូសិន ភីអិលស៊ី
៤៦. ខេមបូឌា ឡេប៊ីរយែរ៍ ភីអិលស៊ី
៤៧. ខឹលេកធីវ វីន (ខេមបូឌា) ភីអិលស៊ី
៤៨. អេស៊ាន ផេស៊ីហ្វិក ហ្វាយនែន
៤៩. ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី
៥០. អ៊ីខេមីតស៊ុ សេហ្សេង ម៉ាយក្រូហ្វាយនែន(ខេមបូឌា)
៥១. ម៉ាខែរ ហ្វាយនែនសល យេផេន ភីអិលស៊ី
៥២. សហការ ភីអិលស៊ី
៥៣. ជោគជ័យ ហ្វាយនែន ភីអិលស៊ី
៥៤. ហ្គោលដិន យែស ភីអិលស៊ី
៥៥. សប្បាយ ក្រេឌីត ខមមើសល ភីអិលស៊ី
៥៦. លីដ ភីអិលស៊ី
៥៧. ជេត យែសបកស៍ ហ្វាយនែន ភីអិលស៊ី
៥៨. ធី&ហ្គូ ហ្វាយនែនភីអិលស៊ី
៥៩. ប្រសិទ្ធិភាព ហ្វាយនែន ភីអិលស៊ី
៦០. អិល ប៊ី ភី មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី
៦១. អនាគត ភីអិលស៊ី
៦២. ប្រ៊្ហូវ ម.ក
៦៣. បៃតង
៦៤. មីយ៉ា ហ្វាយនែនសល ភីអិលស៊ី
៦៥. ពន្លឺចតុមុខ ភីអិលស៊ី
៦៦. វិថី ម៉ាយក្រូហ្វាយនែន ម.ក
៦៧. ទ្រព្យខ្ញុំ ម.ក
៦៨. ខ្មែរ យែភីថល ម .ក
៦៩. ភីជី ឌីវេឡុបមិន ម.ក

### ៧ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ

១. អម្រឹត
២. ហត្ថាកសិករ
៣. អេ អឹម ខេ
៤. វីសិនហ្វាន់ ខេមបូឌា
៥. ក្រេឌីត
៦. ប្រាសាក់
៧. អិល អូ អិល ស៊ី

## ១១ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ

១. ជីអិល ហ្វាយនែន ភីអិលស៊ី
២. ប៊ីអេសភី ហ្វាយនែន (ខេមបូឌា) ម.ក
៣. មេហ្គា លីស៊ីង ភីអិលស៊ី
៤. សួស្តី ហ្វាយនែន ភីអិលស៊ី
៥. ខេខេហ្វាន់ លីស៊ីង ភីអិលស៊ី
៦. តូយ៉ូតា ស៊ុយស៊ូ ហ្វាយនែន ភីអិលស៊ី
៧. អេលីន លីស៊ីង ភីអិលស៊ី
៨. ឡឺរ៉ូស៊េ ហ្វាយនែនសល លីស៊ីង ភីអិលស៊ី
៩. អាយ ហ្វាយនែន ភីអិលស៊ី
១០. លី ហ្វូរ លីស៊ីង ភីអិលស៊ី
១១. ឆាយលីស រ៉ូយ៉ាល់ លីស៊ីង ម.ក

## ១- ក្រុមហ៊ុន ក្រេឌីតប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី

## ២១ សាខាធនាគារជាតិនៅតាមខេត្ត

១. ភ្នំពេញ
២. កំពង់ចាម
៣. ព្រះសីហនុ
៤. សៀមរាប
៥. បាត់ដំបង
៦. បន្ទាយមានជ័យ
៧. ស្វាយរៀង
៨. កណ្តាល
៩. កំពត
១០. កំពង់ធំ
១១. ពោធិសាត់
១២. កំពង់ស្ពឺ
១៣. កោះកុង
១៤. រតនៈគីរី
១៥. ព្រៃវែង
១៦. តាកែវ
១៧. កំពង់ឆ្នាំង
១៨. ព្រះវិហារ
១៩. ក្រចេះ
២០. ស្ទឹងត្រែង
២១. មណ្ឌលគីរី

## ១២ គ្រឹះស្ថានផ្តល់សេវាទូទាត់

១. ក្រុមហ៊ុន អ៊ី ម៉ានី
២. ក្រុមហ៊ុន វីង
៣. ក្រុមហ៊ុន ទ្រូ ម៉ានី
៤. ក្រុមហ៊ុន លី ហ្វូរ វេរលុយ
៥. ក្រុមហ៊ុន Smart Axiata Co., Ltd.
៦. ក្រុមហ៊ុន ផេ ហ្គូស៊ី
៧. ក្រុមហ៊ុន អាស៊ី វេរលុយ
៨. ក្រុមហ៊ុន ស៊ី ថេល
៩. ក្រុមហ៊ុន ផាយ ផេ
១០. ក្រុមហ៊ុន ស្ពីត ផេ (Speed Pay)
១១. ក្រុមហ៊ុន Canadia-Fullerton Mobile Money Co., Ltd.
១២. ក្រុមហ៊ុន XPRESS MONEY SERVICE LIMPTED

## ៣ តតិយភាគី

១. ក្រុមហ៊ុន Western Union Network (Ireland) Ltd.
២. ក្រុមហ៊ុន Money Gram Payment System, Inc
៣. ក្រុមហ៊ុន អាយ អឹម អ៊ី (អ៊ឹម) អែស ឌី អិន ប៊ីអេចឌី

# ឧបសម្ព័ន្ធ៥

## ប្រព័ន្ធ FAST Payment និង Cambodian Shared Switch (CSS)

ក្នុងគោលបំណងជំរុញការប្រើប្រាស់ប្រាក់រៀលនិងការទូទាត់សងប្រាក់អេឡិចត្រូនិកឱ្យកាន់តែមានប្រសិទ្ធភាព ព្រមទាំងលើកកម្ពស់ការធ្វើទំនើបកម្មប្រព័ន្ធទូទាត់នៅកម្ពុជា ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការជាផ្លូវការនូវប្រព័ន្ធសម្រាប់សេវាទូទាត់រហ័ស (Fast Payment System) ដែលប្រព័ន្ធនេះអាចឱ្យអតិថិជនទទួលបានមូលនិធិភ្លាមៗ ឆ្លើយតបទៅនឹងតម្រូវការសាច់ប្រាក់បានទាន់ពេលវេលា។ បច្ចុប្បន្នមានគ្រឹះស្ថានសមាជិកចំនួន ២០ បានដាក់ឱ្យដំណើរការសេវានេះដល់អតិថិជនរបស់ខ្លួន ចំណែកឯគ្រឹះស្ថានធនាគារពាណិជ្ជនិងមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើដទៃទៀត បាននិងកំពុងរៀបចំហេដ្ឋារចនាសម្ព័ន្ធផ្ទៃក្នុងរបស់ខ្លួន និងធ្វើសមាហរណកម្មប្រព័ន្ធ (system integration)។ ដើម្បីពង្រីកការប្រើប្រាស់សេវាទូទាត់រហ័សឱ្យកាន់តែទូលំទូលាយ និងផ្តល់ភាពងាយស្រួលដល់អតិថិជន ធនាគារជាតិនៃកម្ពុជាបាននិងកំពុងជំរុញគ្រឹះស្ថានជាសមាជិក ឱ្យបន្តអភិវឌ្ឍបណ្តាញផ្តល់សេវាបន្ថែមទៀត តាមរយៈប្រតិបត្តិការធនាគារចល័ត ប្រតិបត្តិការអនឡាញ និងឧបករណ៍ទូទាត់ផ្សេងទៀត។

ទន្ទឹមនេះដែរ កាលពីថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការបឋមប្រព័ន្ធ Cambodian Shared Switch (CSS) ដោយមានគ្រឹះស្ថានសមាជិកចំនួន ៣ ចូលរួមក្នុងដំណាក់កាលដំបូងនេះ។ ម្យ៉ាងវិញទៀត ក្រៅពីគ្រឹះស្ថានចំនួនបីនេះ គ្រឹះស្ថានធនាគារពាណិជ្ជនិងមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើដទៃទៀត បាននិងកំពុងដាក់ពាក្យចូលជាសមាជិកប្រព័ន្ធ និងបន្តធ្វើសន្ទានកម្មប្រព័ន្ធជាបន្តបន្ទាប់។ ប្រព័ន្ធ CSS ជាប្រព័ន្ធរួមមួយសម្រាប់សម្រួលដល់ប្រតិបត្តិការទូទាត់អន្តរធនាគារ តាមរយៈប័ណ្ណទូទាត់ឥណពន្ធលើម៉ាស៊ីន ATM និងម៉ាស៊ីន POS ក្នុងគោលដៅបង្កើននូវប្រសិទ្ធភាពសេវាទូទាត់ កាត់បន្ថយចរាចរសាច់ប្រាក់នៅលើទីផ្សារ និងដើម្បីឆ្លើយតបទៅនឹងតម្រូវការសមាហរណកម្មអាស៊ាននាពេលខាងមុខ។

## ឧបសម្ព័ន្ធ៦

# បញ្ជីលេខទូរសព្ទទំនាក់ទំនងអំពីចម្ងល់ និងបញ្ហាពាក់ព័ន្ធនឹងការប្រើប្រាស់សេវាហិរញ្ញវត្ថុ

### ធនាគារជាតិនៃកម្ពុជា ស្នាក់ការកណ្តាល

| | | |
|---|---|---|
| ០៨៥ ៦០០ ០០២ | ០៨៥ ៦០០ ០០៣ | ០៩៨ ២២០ ០០១ |
| ០៩៨ ២២០ ០០២ | ០៩៧ ២៧៨ ៣០៣០ | |

### សាខារាជធានី-ខេត្ត

| | |
|---|---|
| រាជធានីភ្នំពេញ | ០១៦ ៥៦៨ ៨៣៣ |
| ខេត្តកណ្តាល | ០១៦ ៥៦៨ ៨៩០ |
| ខេត្តកំពង់ចាម | ០១៦ ៥៦៨ ៨១២ |
| ខេត្តបាត់ដំបង | ០១៦ ៥៦៨ ១១៥ |
| ខេត្តព្រៃវែង | ០១៦ ៥៦៨ ៨២០ |
| ខេត្តសៀមរាប | ០១៦ ៥៦៨ ១៧៥ |
| ខេត្តកំពង់ធំ | ០១៦ ៥៦៨ ៥៨២ |
| ខេត្តតាកែវ | ០១៦ ៥៦៨ ១៦២ |
| ខេត្តស្វាយរៀង | ០១៦ ៥៦៨ ៨២៥ |
| ខេត្តពោធិ៍សាត់ | ០១៦ ៥៦៨ ៨៩៩ |
| ខេត្តកំពង់ឆ្នាំង | ០១៦ ៦៨៧ ២២០ |
| ខេត្តកំពង់ស្ពឺ | ០១៦ ៦៨៧ ២២៩ |
| ខេត្តកំពត | ០១៦ ៦៨៧ ៣៣០ |
| ខេត្តព្រះសីហនុ | ០១៦ ៦៨៧ ១៩៥ |
| ខេត្តកោះកុង | ០១៦ ៦៨៧ ៣៨០ |
| ខេត្តព្រះវិហារ | ០១៦ ៦៨៧ ២៩៨ |
| ខេត្តក្រចេះ | ០៨៦ ៣៥៥ ០៧០ |
| ខេត្តរតនគិរី | ០៩៦ ៧១៨១ ៨៥៣ |
| ខេត្តមណ្ឌលគិរី | ០៩៦ ៧១៧៨ ២៦៥ |
| ខេត្តស្ទឹងត្រែង | ០៩៦ ៧១៧៩ ៨១៥ |
| ខេត្តបន្ទាយមានជ័យ | ០៩៦ ៧៨៦៧ ៦៩៩ |